ព័ត៌មានអំពីការបោះឆ្នោតតាមសំបុត្របានភ្ជាប់មកជាមួយ!

Massachusetts

# ព័ត៌មានសម្រាប់អ្នកបោះឆ្នោត

## សំណួរអំពីសន្លឹកឆ្នោត 2020

## ការបោះឆ្នោតរដ្ឋ

### ថ្ងៃអង្គារ ទី 3 ខែវិច្ឆិកា ឆ្នាំ 2020

ទម្រង់ចុះឈ្មោះបោះឆ្នោតផ្ញើតាមសំបុត្រត្រូវបានភ្ជាប់មកជាមួយ !

ចុះឈ្មោះបោះឆ្នោតតាមអ៊ីនធឺណិតនៅរដ្ឋ Massachusetts

**registertovotema.com**

*បោះពុម្ពផ្សាយដោយ*

**William Francis Galvin**

លេខាធិការរដ្ឋសហាធន

# *The Commonwealth of Massachusetts*

## *Secretary of the Commonwealth*

*State House, Boston, Massachusetts 02133*

*William Francis Galvin*
*Secretary of the Commonwealth*

ជូនចំពោះអ្នកបោះឆ្នោតជាទីរាប់អាន ៖

នេះគឺជាឆ្នាំដ៏លំបាកមួយសម្រាប់ប្រជាពលរដ្ឋរបស់យើងទាំងអស់ ប៉ុន្តែឥឡូវនេះដូចកាលនៅក្នុងពេលលំបាកពីមុនអញ្ចឹង ប្រជាជនពលរដ្ឋ Massachusetts តែងតែប្រឈមនឹងបញ្ហានានា ហើយមិនដែលអនុញ្ញាតឱ្យស្ថានភាពទាំងនេះរារាំងពួកគេមិនឱ្យបញ្ចេញមតិរបស់ពួកគេ និងប្រើសិទ្ធិរបស់ពួកគេក្នុងការជ្រើសរើសមេដឹកនាំរបស់យើង និងធ្វើការសម្រេចចិត្តលើគោលនយោបាយបានឡើយ ។

ឆ្នាំនេះ ដើម្បីជួយអ្នកបោះឆ្នោតឱ្យចូលរួម ខ្ញុំបានផ្តួចផ្តើមនីតិវិធីថ្មីដើម្បីផ្តល់ជម្រើសកាន់តែច្រើនដល់អ្នកបោះឆ្នោត ។ យើងបានណែនាំការបោះឆ្នោតតាមសំបុត្រជាជម្រើសមួយដែលបានបង្កើនចំនួនថ្ងៃបោះឆ្នោតមុនកាលកំណត់ចាប់ពីថ្ងៃទី 17 ដល់ថ្ងៃទី 30 ខែតុលា ហើយយើងកំពុងធ្វើការធានាថាអ្នក ដែលជ្រើសរើសបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020 នឹងអាចធ្វើដូច្នេះដោយសុវត្ថិភាព ។ ការិយាល័យបោះឆ្នោតទាំងអស់នឹងត្រូវបើកពីម៉ោង 7:00 ព្រឹកដល់ 8:00 យប់ ។

បើអ្នកមិនទាន់បានចុះឈ្មោះបោះឆ្នោត ឬត្រូវការចុះឈ្មោះឡើងវិញ ពីព្រោះអ្នកបានផ្លាស់ទីលំនៅ យើងបានភ្ជាប់មកជាមួយនូវទម្រង់សម្រាប់អ្នកបំពេញ និងផ្ញើតាមសំបុត្រត្រឡប់មកវិញ ឬប្រសិនបើអ្នកមានប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណរបស់រដ្ឋ Massachusetts អ្នកអាចចុះឈ្មោះបោះឆ្នោតតាមអ៊ីនធឺណិតនៅលើគេហទំព័រ **www.RegisterToVoteMA.com** ។ ច្បាប់រដ្ឋតម្រូវឲ្យអ្នកត្រូវតែចុះឈ្មោះនៅត្រឹមថ្ងៃទី 24 ខែតុលា ឆ្នាំ 2020 ដើម្បីឱ្យឈ្មោះរបស់អ្នកមាននៅលើបញ្ជីឈ្មោះបោះឆ្នោត ។ អ្នកក៏អាចពិនិត្យមើលស្ថានភាពចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកនៅលើគេហទំព័ររបស់យើងផងដែរ ។

មានសំណួរពីរទាក់ទងនឹងសន្លឹកឆ្នោតស្របច្បាប់ទូទាំងរដ្ឋដែលបង្ហាញនៅលើសន្លឹកឆ្នោតនៃការបោះឆ្នោតរបស់រដ្ឋ ។ ព័ត៌មានផ្លូវការឆ្នាំ 2020 សម្រាប់កូនសៀវភៅអ្នកបោះឆ្នោត មានបញ្ជីសំណួរនីមួយៗដែលមានអត្ថបទច្បាប់ដែលបានស្នើឡើង សេចក្តីថ្លែងការណ៍ដែលរៀបរាប់អំពីផលប៉ះពាល់ពីការបោះឆ្នោតគាំទ្រ ឬប្រឆាំង សេចក្តីសង្ខេប និងសេចក្តីអះអាងសង្ខេបគាំទ្រ និងជំទាស់នឹងសំណួរនីមួយៗ ។ ព័ត៌មាននេះនឹងជួយអ្នកក្នុងការសម្រេចចិត្តគិតគូរហ្មត់ចត់មុនពេលអ្នកបោះឆ្នោត ។ អ្នកអាចយកកូនសៀវភៅនេះទៅជាមួយអ្នកចូលទៅក្នុងតូបបោះឆ្នោតបាន ប្រសិនបើអ្នកចង់ ។

កូនសៀវភៅនេះមានព័ត៌មានសំខាន់ៗអំពីការបោះឆ្នោតនាពេលខាងមុខនេះ ។ ជម្រើសដែលលោកអ្នកអនុវត្តនៅក្នុងការបោះឆ្នោតនេះ នឹងកំណត់គោលដៅរដ្ឋាភិបាលសម្រាប់សហគមន៍ជាតិ រដ្ឋ និងមូលដ្ឋានរបស់យើង ។ អ្នកដឹកនាំដែលលោកអ្នកជ្រើសរើស នឹងធ្វើការសម្រេចចិត្តសំខាន់ៗដែលមានផលប៉ះពាល់ដល់លោកអ្នក និងគ្រួសាររបស់អ្នក ។ ខ្ញុំជំរុញលើកទឹកចិត្តអ្នកឱ្យចូលរួមក្នុងដំណើរការនេះ ពីព្រោះសំឡេងឆ្នោតរបស់អ្នកមានសារៈសំខាន់ ។

សូមបោះឆ្នោត និងអនុវត្តសិទ្ធិចាំបាច់បំផុតនៃប្រព័ន្ធប្រជាធិបតេយ្យរបស់យើង ។

ដោយក្តីគោរពខ្ពង់ខ្ពស់,

William Francis Galvin

William Francis Galvin
លេខាធិការរដ្ឋសហធន

## *ការិយាល័យនានានៅលើសន្លឹកឆ្នោតឆ្នាំ 2020*

**ប្រធាន/អនុប្រធាន**

**សមាជិកព្រឹទ្ធសភានៅក្នុងសភា**

**អ្នកតំណាងនៅក្នុងសភា**

**ក្រុមប្រឹក្សា**

**សមាជិកព្រឹទ្ធសភានៅតុលាការធម្មតា**

**អ្នកតំណាងនៅតុលាការធម្មតា**

**ការចុះបញ្ជីលិខិតមរតក**

**ស្នងការខោនធី**

(សម្រាប់តែខោនធី Barnstable, Bristol, Dukes, Norfolk និង Plymouth ប៉ុណ្ណោះ) ឬក្រុមប្រឹក្សារដ្ឋាភិបាល Franklin (សម្រាប់តែខោនធី Franklin ប៉ុណ្ណោះ)

**ហិរញ្ញិកខោនធី**

(សម្រាប់តែខោនធី Bristol, Dukes, Norfolk និង Plymouth ប៉ុណ្ណោះ)

**នគរបាល**

(សម្រាប់តែខោនធី Norfolk ប៉ុណ្ណោះ – ដើម្បីបំពេញកន្លែងនៅទំនេរ)

## *កាលកំណត់ចុះឈ្មោះបោះឆ្នោត!*

សូមពិនិត្យមើលការចុះឈ្មោះបោះឆ្នោតរបស់អ្នកលើគេហទំព័រ **www.RegistertovoteMA.com** ។

បើអ្នកមិនត្រូវបានចុះឈ្មោះទេ អ្នកអាចប្រើទម្រង់ដែលភ្ជាប់មកជាមួយ ដើម្បីចុះឈ្មោះ ប៉ុន្តែវាត្រូវតែបានបង់ថ្លៃប្រៃសណីយ៍ត្រឹមថ្ងៃទី **24 ខែ តុលា ឆ្នាំ 2020** ដើម្បីឱ្យអ្នកមានសិទ្ធិបោះឆ្នោតក្នុងការបោះឆ្នោតរបស់រដ្ឋ ។




**ទម្រង់ចុះឈ្មោះបោះឆ្នោតផ្ញើតាមសំបុត្រត្រូវបានភ្ជាប់មកជាមួយ !**

ដើម្បីទទួលបានទម្រង់ចុះឈ្មោះបោះឆ្នោតតាមសំបុត្របន្ថែមទៀត សូមចូលមើលគេហទំព័ររបស់យើងតាមអាសយដ្ឋាន **www.sec.state.ma.us/ele** ឬទូរស័ព្ទមកនាយកដ្ឋានបោះឆ្នោតតាមលេខ 617-727-2828 ឬ 1-800-462-VOTE ។

## *មាតិកា*

សំណួរទី 1 - ទិន្នន័យមេកានិចនៃយានយន្ត....................................4
សំណួរទី 2 - ការបោះឆ្នោតទៅតាមលំដាប់នៃជម្រើស ..............................7
ការបោះឆ្នោតនៅឆ្នាំ 2020 ..........................................................12
ការចុះឈ្មោះបោះឆ្នោត ..............................................................12
ការបោះឆ្នោតតាមសំបុត្រ… ........................................................13
ការបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់មុនកាលកំណត់.........................14
ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត.......................................................15
សំណួរដែលគេសួរជាញឹកញាប់ .......................................................16
បញ្ឈប់ការរីករាលដាលនៃមេរោគ....................................................17
ធ្វើជាមន្ត្រីរៀបចំការបោះឆ្នោត ......................................................18
អ្នកបោះឆ្នោតជាយោធា និងនៅបរទេស ...........................................18
ប្រសិនបើលោកអ្នកជាជនរងគ្រោះពីការក្លែងបន្លំការវិនិយោគ.....................19
សេវាកម្មនៃលេខាធិការសហគមន៍ឯករាជ្យនៃរដ្ឋម៉ាសាឈូសេត Massachusetts ................................................................20
ជំនួយសម្រាប់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ ................................21
សេចក្តីប្រកាសសិទ្ធិឯកជនរបស់អ្នកបោះឆ្នោតនៅរដ្ឋ Massachusetts ....22
បញ្ជីឈ្មោះផ្ទៀងផ្ទាត់អ្នកបោះឆ្នោត..................................................23

សូមយកចិត្តទុកដាក់! ប្រសិនបើអ្នកចង់បានឯកសារនេះជាភាសាខ្មែរ សូមអ្នកទូរស័ព្ទទៅលេខ 617-727-2828 ឬ 1-800-462-VOTE (8683) ។

¡Atención! Si desea recibir este folleto en Español, llame al 617-727-2828 o al 1-800-462-VOTE (8683).

請注意！如果您希望索取本手冊的中文譯本，請致電 617-727-2828 或 1-800-462-8683。

# 1

## សំណួរទី 1 ៖ ច្បាប់ដែលបានស្នើឡើងដោយបដ្ឋនាលិខិតផ្តួចផ្តើម

# ទិន្នន័យមេកានិចនៃយានយន្ត

*តើអ្នកយល់ព្រមចំពោះច្បាប់ដែលបានសង្ខេបខាងក្រោមដែលក្នុងនោះការបោះឆ្នោតប្រឆាំងត្រូវបានទទួលយកដោយព្រឹទ្ធសភា ឬសភាតំណាងរាស្ត្រនៅថ្ងៃ ឬមុនថ្ងៃទី 5 ខែឧសភា ឆ្នាំ 2020 ដែរឬទេ ?*

**សេចក្តីសង្ខេប ▶**
តាមដែលច្បាប់តម្រូវ សេចក្តីសង្ខេបត្រូវបានសរសេរដោយអគ្គមេធាវីរបស់រដ្ឋ ។

ច្បាប់ដែលបានស្នើឡើងនេះនឹង តម្រូវឱ្យម្ចាស់រថយន្ត និងយានដ្ឋានជួសជុលរថយន្តឯករាជ្យទទួលបានលទ្ធភាពច្រើនក្នុងការទទួលបានទិន្នន័យមេកានិចដែលទាក់ទងនឹងការថែទាំ និងជួសជុលរថយន្ត ។

ចាប់ពីឆ្នាំគំរូ 2022 ច្បាប់ដែលបានស្នើឡើងនេះនឹងតម្រូវឲ្យអ្នកផលិតរថយន្តដែលលក់នៅរដ្ឋ Massachusetts បំពាក់រថយន្តទាំងនេះដែលប្រើប្រព័ន្ធតេឡេម៉ាទិច ដែលជាប្រព័ន្ធប្រមូល និងបញ្ជូនទិន្នន័យមេកានិចដោយឥតខ្សែទៅកាន់ម៉ាស៊ីនមេពីចម្ងាយ ដែលមានវេទិកាទិន្នន័យដំណើរការបើកចំហរជាលក្ខណៈស្តង់ដារ ។ ម្ចាស់រថយន្តដែលមានបំពាក់ប្រព័ន្ធតេឡេម៉ាទិចអាចទទួលបានទិន្នន័យមេកានិចតាមរយៈកម្មវិធីឧបករណ៍ចល័ត ។ ដោយមានការអនុញ្ញាតពីម្ចាស់រថយន្ត យានដ្ឋានជួសជុលរថយន្តឯករាជ្យ(ដែលមិនជាប់ពាក់ព័ន្ធជាមួយក្រុមហ៊ុនផលិត)និងឃ្លាំងលក់រថយន្តឯករាជ្យនឹងអាចទាញយកទិន្នន័យមេកានិចពី និងបញ្ជូនការបញ្ជាទៅរថយន្តសម្រាប់ជួសជុល ថែទាំ និងធ្វើតេស្តវិភាគរកបញ្ហា ។

យោងតាមច្បាប់ដែលបានស្នើឡើងនេះ ក្រុមហ៊ុនផលិតនឹងមិនត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិអនុញ្ញាតមុនពេលម្ចាស់រថយន្ត ឬយានដ្ឋានជួសជុលរថយន្តអាចចូលមើលទិន្នន័យមេកានិចដែលផ្ទុកនៅក្នុងប្រព័ន្ធវិភាគរកបញ្ហារបស់រថយន្តនោះទេ លើកលែងតែតាមរយៈដំណើរការនៃការអនុញ្ញាតដែលមានលក្ខណៈស្តង់ដារគ្រប់ម៉ាក និងម៉ូដែល និងគ្រប់គ្រងដោយអង្គភាពដែលមិនជាប់ពាក់ព័ន្ធជាមួយក្រុមហ៊ុនផលិត ។

ច្បាប់ដែលបានស្នើឡើងនេះនឹងតម្រូវឱ្យអគ្គព្រះរាជអាជ្ញារៀបចំសេចក្តីជូនដំណឹងដល់អនាគតម្ចាស់រថយន្ត និងអ្នកជួល ដែលពន្យល់ពីតេឡេម៉ាទិច និងលក្ខខណ្ឌច្បាប់ដែលបានស្នើឡើងនេះទាក់ទងនឹងការចូលមើលទិន្នន័យមេកានិចរបស់រថយន្ត ។ តាមច្បាប់ដែលបានស្នើឡើងនេះ ម្ចាស់ឃ្លាំងលក់រថយន្តត្រូវផ្តល់ឱ្យម្ចាស់អនាគត ហើយម្ចាស់អនាគតត្រូវទទួលស្គាល់នូវការទទួលការជូនដំណឹងមុនពេលទិញ ឬជួលរថយន្ត ។ ការមិនអនុលោមតាមលក្ខខណ្ឌនៃសេចក្តីជូនដំណឹងទាំងនេះនឹងធ្វើឱ្យម្ចាស់ឃ្លាំងលក់រថយន្តទទួលរងការដាក់ទណ្ឌកម្មពីអាជ្ញាធរចេញអាជ្ញាប័ណ្ណ ។

ម្ចាស់រថយន្ត និងយានដ្ឋានជួសជុលរថយន្តឯករាជ្យអាចអនុវត្តច្បាប់នេះតាមរយៈច្បាប់រដ្ឋស្តីពីការការពារអ្នកប្រើប្រាស់ និងទារវិញនូវប្រាក់ពិន័យរដ្ឋប្បវេណីលើសំណងខូចខាតដែលមានទំហំបីដង

---

**អ្វីដែលសន្លឹកឆ្នោតរបស់អ្នកនឹងធ្វើ ▶**
តាមដែលច្បាប់តម្រូវ សេចក្តីថ្លែងការណ៍ដែលរៀបរាប់អំពីផលប៉ះពាល់នៃការបោះឆ្នោត “គាំទ្រ” ឬ “ប្រឆាំង” ត្រូវបានសរសេររួមគ្នាដោយអគ្គមេធាវីរបស់រដ្ឋ និងលេខាធិការរដ្ឋសហធន ។

***ការបោះឆ្នោតគាំទ្រ*** នឹងផ្តល់ជូនម្ចាស់យានយន្ត និងយានដ្ឋានជួសជុលឯករាជ្យនូវលទ្ធភាពពង្រីកទិន្នន័យមេកានិចដែលបញ្ជូនឥតខ្សែទាក់ទងនឹងការថែទាំ និងជួសជុលយានយន្តរបស់ពួកគេ ។

***ការបោះឆ្នោតប្រឆាំង*** នឹងមិនផ្លាស់ប្តូរច្បាប់គ្រប់គ្រងការចូលប្រើទិន្នន័យមេកានិចដែលបញ្ជូនឥតខ្សែរបស់យានយន្តទេ ។

---

**សេចក្តីថ្លែងការណ៍អំពីផលវិបាកនៃសារពើពន្ធ ▶**
តាមដែលច្បាប់តម្រូវ សេចក្តីថ្លែងការណ៍អំពីផលវិបាកនៃសារពើពន្ធត្រូវបានសរសេរដោយការិយាល័យប្រតិបត្តិផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ។

ច្បាប់ដែលបានស្នើឡើងនេះមិនមានផលវិបាកនៃសារពើពន្ធជាសារវ័ន្តជាក់ស្តែងសម្រាប់ហិរញ្ញវត្ថុរបស់រដ្ឋ និងសាលាក្រុងទេ ។

# សំណួរទី 1 ៖ ច្បាប់ដែលបានស្នើឡើងដោយបដ្ឋនាលិខិតផ្តួចផ្តើម

**សេចក្តីអះអាង ▶**

តាមដែលច្បាប់តម្រូវ សេចក្តីអះអាងដែលមាន 150 ពាក្យត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកប្រឆាំងសំណួរនីមួយៗ និងបង្ហាញអំពីមតិយោបល់របស់ពួកគេ ។ រដ្ឋសហាធន Massachusetts មិនយល់ព្រមចំពោះសេចក្តីអះអាងទាំងនេះទេ ហើយមិនបញ្ជាក់ភាពពិត ឬភាពត្រឹមត្រូវនៃសេចក្តីថ្លែងការណ៍ណាមួយដែលបានធ្វើឡើងនៅក្នុងសេចក្តីអះអាងទាំងនេះឡើយ ។ ឈ្មោះរបស់បុគ្គល និងអង្គភាពនានាដែលបានសរសេរសេចក្តីអះអាងនីមួយៗ និងមតិយោបល់ណាមួយដែលសរសេរជាលាយលក្ខណ៍អក្សរដោយអ្នកដទៃទៀតអំពីសេចក្តីអះអាងនីមួយៗនោះ មាននៅក្នុងឯកសារនៅការិយាល័យលេខាធិការរដ្ឋសហាធន ។

***ការគាំទ្រ ៖*** ការបោះឆ្នោតគាំទ្រសិទ្ធិក្នុងការជួសជុលនឹងធានាថា នៅពេលបច្ចេកវិទ្យារីកចម្រើន អ្នកបើកបរអាចបន្តជួសជុលរថយន្តរបស់ពួកគេនៅកន្លែងណាដែលពួកគេចង់បាន ។

យើងបានអនុម័តសិទ្ធិដំបូងនៃច្បាប់ជួសជុលក្នុងឆ្នាំ 2012 ប៉ុន្តែនៅពេលដែលរថយន្តថ្មីៗប្រើប្រព័ន្ធកុំព្យូទ័រកាន់តែច្រើនឡើង ក្រុមហ៊ុនផលិតរថយន្តកំពុងប្រើប្រាស់ចន្លោះប្រហោងដើម្បីរឹតត្បិតការចូលប្រើទិន្នន័យដែលត្រូវការដើម្បីវិភាគរកបញ្ហា ធ្វើការជួសជុល និងអនុវត្តការថែទាំ ។

នេះមានន័យថាម្ចាស់រថយន្តត្រូវទៅរកជម្រើសជួសជុលកាន់តែថ្លៃរបស់ឈ្មួញ ។ សូមបោះឆ្នោតគាំទ្រដើម្បីការពារហាងជួសជុលឯករាជ្យ និងរក្សាសមត្ថភាពរបស់អ្នកក្នុងការជ្រេតម្លៃ ។

ការបោះឆ្នោតគាំទ្រផ្តល់ជូនសិទ្ធិចូលប្រើព័ត៌មានមេកានិច និងជួសជុលតែប៉ុណ្ណោះ មិនមែនព័ត៌មានផ្ទាល់ខ្លួនទេ ។

ការបោះឆ្នោតគាំទ្រនឹងធានាថា អ្នកនឹងមានជម្រើសក្នុងការផ្តល់សិទ្ធិចូលមើលព័ត៌មានអំពីការជួសជុលដែលចាំបាច់ ដើម្បីជួសជុលរថយន្តរបស់អ្នកដល់ហាងជួសជុលឯករាជ្យក្នុងតំបន់របស់អ្នកទោះបីជារថយន្តប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រកាន់តែច្រើនឡើងក៏ដោយ ។

វាជារថយន្តរបស់អ្នក អ្នកបានបង់លុយ អ្នកគួរតែជួសជុលវានៅកន្លែងដែលអ្នកចង់បាន ។

**Tommy Hickey**
**Massachusetts Right to Repair**
**9 Park Street, #5**
**Boston, MA 02108**
**617-248-9772**
**massrighttorepair.org**

***ប្រឆាំង ៖*** បោះឆ្នោតប្រឆាំងសំណួរទី 1 ដើម្បីការពារសិទ្ធិឯកជន សុវត្ថិភាព និងក្រុមគ្រួសាររបស់អ្នក ។

សំណួរទី 1 គ្មានអ្វីទាក់ទងនឹងការជួសជុលរថយន្តទេ ។ សំណួរទី 1 គឺជាការចាប់យកទិន្នន័យដោយភាគីទីបីដែលចង់ប្រមូលព័ត៌មានយានយន្តផ្ទាល់ខ្លួនរបស់អ្នក ហើយចូលមើលព័ត៌មាននេះពីចម្ងាយរួមទាំងទិន្នន័យទីតាំងក្នុងពេលវេលាជាក់ស្តែង ។

អ្នកគាំពារខាងអំពើហិង្សាក្នុងគ្រួសារព្រមានថា ព័ត៌មាននេះអាចមានគ្រោះថ្នាក់ដល់កម្រិតណា ។ Jane Doe មកពីសម្ព័ន្ធភាពនៃរដ្ឋ Massachusetts ប្រឆាំងនឹងការបំពានផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារបានសរសេរថា "ការទទួលបានទិន្នន័យយានយន្ត ជាពិសេសកំណត់ហេតុហៅទូរស័ព្ទ និងទីតាំង GPS អាចអនុញ្ញាតឲ្យអ្នកដែលរំលោភបំពានបំពានប្រើឧបករណ៍ដែលចាំបាច់ដើម្បីតាមដាន និងតាមដានជនរងគ្រោះរបស់ពួកគេ" ។ សេចក្តីស្នើស្រដៀងគ្នានេះបានបរាជ័យនៅក្នុងរដ្ឋ California បន្ទាប់ពីសម្ព័ន្ធភាពរដ្ឋ California ប្រឆាំងនឹងការរំលោភផ្លូវភេទបានព្រមានថា "ពីព័ត៌មាននេះ ភាគីទីបីដូចជាជនរំលោភផ្លូវភេទអាចតាមដានរំខាន និង/ឬធ្វើទុក្ខទោសដល់ជនរងគ្រោះ" ។

អ្នកគាំពារសិទ្ធិឯកជន អ្នកជំនាញខាងផ្នែកសន្តិសុខតាមអ៊ីនធឺណិត និងក្រុមគាំពារប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារជំរុញឱ្យអ្នកបោះឆ្នោតប្រឆាំងសំណួរទី 1 ។

**Steve McElhinney**
**Coalition for Safe and Secure Data**
**177 Milk Street, Suite 610**
**Boston, MA 02109**
**617-398-0281**
**Safeandsecuredata.org**

## អត្ថបទទាំងស្រុងនៃសំណួរ

វាត្រូវអនុម័តដោយប្រជាពលរដ្ឋ និងដោយអាជ្ញាធររបស់ពួកគេ ៖

ផ្នែកទី 1. ផ្នែកទី 1 នៃជំពូកទី 93K នៃច្បាប់ទូទៅត្រូវបានធ្វើវិសោធនកម្មដោយបញ្ចូលបន្ទាប់ពីនិយមន័យនៃ "ក្រុមហ៊ុនផលិត" នូវនិយមន័យដូចខាងក្រោម ៖— "ទិន្នន័យមេកានិច" ដែលជាទិន្នន័យជាក់លាក់នៃរថយន្តណាមួយ រួមទាំងទិន្នន័យប្រព័ន្ធតេឡេម៉ាទិចដែលត្រូវបានបង្កើត រក្សាទុក ឬបញ្ជូនដោយរថយន្តដែលត្រូវបានប្រើសម្រាប់ ឬទាក់ទងនឹងការវិនិច្ឆ័យ ជួសជុល ឬថែទាំរថយន្ត ។ ផ្នែកទី 1 នៃជំពូកទី 93K នេះត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយបញ្ចូលបន្ទាប់ពីនិយមន័យនៃ "ម្ចាស់" នូវនិយមន័យថ្មីដូចខាងក្រោមនេះ ៖— "ប្រព័ន្ធតេឡេម៉ាទិច" ជាប្រព័ន្ធណាមួយនៅក្នុងរថយន្តដែលប្រមូលព័ត៌មានដែលបង្កើតឡើងដោយប្រតិបត្តិការរបស់រថយន្ត ហើយបញ្ជូនព័ត៌មានទាំងនោះ ដែលនៅក្នុងជំពូកនេះត្រូវបានហៅថា "ទិន្នន័យប្រព័ន្ធតេឡេម៉ាទិច" ដោយប្រើប្រាស់ការទំនាក់ទំនងឥតខ្សែទៅកាន់ចំណុចទទួលបានពីចម្ងាយ ជាកន្លែងដែលវាត្រូវបានរក្សាទុក ។

ផ្នែកទី 2. ផ្នែកទី 2 (d) (1) នៃជំពូកទី 93K ត្រូវបានធ្វើវិសោធនកម្មដោយបញ្ចូលនៅចុងបញ្ចប់នៃផ្នែកនោះនូវកថាខណ្ឌថ្មីដូចខាងក្រោម ៖ បើទោះបីជាមានចែងអ្វីនៅក្នុងកថាខណ្ឌមុនក្តី ក៏សិទ្ធិរបស់ម្ចាស់រថយន្ត និងយានដ្ឋានជួសជុលឯករាជ្យទៅលើប្រព័ន្ធវិនិច្ឆ័យលើរថយន្តត្រូវមានលក្ខណៈស្តង់ដារ និងមិនតម្រូវឱ្យមានការអនុញ្ញាតពីក្រុមហ៊ុនផលិត ដោយផ្ទាល់ ឬដោយប្រយោលឡើយ លើកលែងតែប្រព័ន្ធអនុញ្ញាតសិទ្ធិលើបណ្តាញរថយន្ត និងប្រព័ន្ធវិនិច្ឆ័យលើរថយន្តរបស់ពួកគេមានលក្ខណៈស្តង់ដារនៅគ្រប់ម៉ាក និងម៉ូដែលទាំងអស់ដែលត្រូវបានដាក់លក់នៅក្នុងរដ្ឋសហាធន និងត្រូវបានគ្រប់គ្រងដោយអង្គភាពដែលមិនមានទំនាក់ទំនងជាមួយក្រុមហ៊ុនផលិត ។

ផ្នែកទី 3. ជំពូកទី 93K នេះត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយលុបចោលផ្នែករង (f) នៃផ្នែកទី 2 និងបញ្ចូលជំនួសវិញដូចខាងក្រោមនេះ ៖— (f) ដោយចាប់ផ្តើមពីម៉ូដែលឆ្នាំ 2022 និងក្រោយៗនោះទៅ ក្រុមហ៊ុនផលិតរថយន្តដែលលក់នៅក្នុងរដ្ឋសហាធននេះ រួមទាំងរថយន្តធុនធ្ងន់ដែលមានទម្ងន់យានសរុបលើសពី 14,000 ផោន ដែលប្រើប្រាស់ប្រព័ន្ធតេឡេ

**អត្ថបទទាំងស្រុងនៃសំណួរ** (ត)

ម៉ាទិចចាំបាច់ត្រូវតែបំពាក់លើរថយន្តនោះនូវកម្មវិធីដែលមានលក្ខណៈអន្តរប្រតិបត្តិការ ស្តង់ដារ និងបើកទូលាយនៅលើគ្រប់ម៉ាក និងម៉ូដែលរបស់ក្រុមហ៊ុនផលិត ។ វេទិកានោះត្រូវមានសមត្ថភាពបញ្ជូនដោយសុវត្ថិភាពនូវទិន្នន័យមេកានិចទាំងអស់ដែលបញ្ចេញពីរថយន្តដោយផ្ទាល់តាមរយៈការតភ្ជាប់ទិន្នន័យដោយផ្ទាល់ទៅកាន់វេទិកានោះ ។ វេទិកានោះត្រូវអាចចូលប្រើដោយផ្ទាល់ដោយម្ចាស់រថយន្តតាមរយៈកម្មវិធីដំណើរការលើទូរសព្ទ ហើយតាមការអនុញ្ញាតពីម្ចាស់រថយន្ត រាល់ទិន្នន័យមេកានិចទាំងអស់ត្រូវអាចចូលប្រើដោយផ្ទាល់ដោយយានដ្ឋានជួសជុលឯករាជ្យ ឬអ្នកចែកចាយថ្នាក់ទី 1 ដែលមានអាជ្ញាបណ្ណស្របតាមផ្នែកទី 58 នៃជំពូកទី 140 ដែលកម្រិតចំពោះពេលវេលាបញ្ចប់ការជួសជុល ឬក្នុងរយៈពេលដែលបានព្រមព្រៀងដោយម្ចាស់រថយន្តក្នុងគោលបំណងថែទាំ ធ្វើការវិនិច្ឆ័យ និងជួសជុលរថយន្ត ។ សិទ្ធិចូលប្រើត្រូវរួមបញ្ចូលនូវសមត្ថភាពក្នុងការបញ្ជូនពាក្យបញ្ជាទៅសមាសធាតុនៅក្នុងរថយន្តទាំងឡាយ ប្រសិនបើចាំបាច់ សម្រាប់គោលបំណងថែទាំ វិនិច្ឆ័យ និងជួសជុល ។

ផ្នែកទី 4. ជំពូកទី 93K នេះត្រូវបានធ្វើវិសោធនកម្មបន្ថែមទៀតដោយបន្ថែមបន្ទាប់ពីផ្នែករង (f) នៃផ្នែកទី 2 ដូចខាងក្រោម ៖

(g) អគ្គមេធាវីត្រូវបានណែនាំឱ្យបង្កើតសម្រាប់អនាគតម្ចាស់រថយន្តនូវសេចក្តីជូនដំណឹងអំពីប្រព័ន្ធតេឡេម៉ាទិចលើរថយន្តដែលរួមមានជាអាទិ៍ដូចជា ៖ (i) ការពន្យល់អំពីតេឡេម៉ាទិចរថយន្ត និងគោលបំណងរបស់វា (ii) ការពិពណ៌នាសង្ខេបអំពីទិន្នន័យមេកានិចដែលត្រូវបានប្រមូល រក្សាទុក និងបញ្ជូនដោយប្រព័ន្ធតេឡេម៉ាទិច (iii) សមត្ថភាពរបស់អនាគតម្ចាស់ក្នុងការចូលប្រើទិន្នន័យមេកានិចរបស់រថយន្តតាមរយៈឧបករណ៍ចល័ត និង (iv) សិទ្ធិរបស់ម្ចាស់ក្នុងការអនុញ្ញាតឱ្យយានដ្ឋានជួសជុលឯករាជ្យចូលប្រើទិន្នន័យមេកានិចរបស់រថយន្តសម្រាប់គោលបំណងវិនិច្ឆ័យ ជួសជុល និងថែទាំរថយន្ត ។ សំណុំបែបបទជូនដំណឹងត្រូវផ្តល់ជូននូវការបញ្ជាក់ដោយមានហត្ថលេខារបស់អនាគតម្ចាស់ថា អនាគតម្ចាស់បានអានសេចក្តីជូនដំណឹងអំពីប្រព័ន្ធតេឡេម៉ាទិច ។

(h) នៅពេលលក់ ឬជួលរថយន្តដែលមានប្រព័ន្ធតេឡេម៉ាទិច អ្នកចែកចាយដែលកាន់អាជ្ញាបណ្ណថ្នាក់ទី 1 ឬថ្នាក់ទី 2 ដូចមានចែងក្នុងផ្នែកទី 58 នៃជំពូកទី 140 ត្រូវផ្តល់ការជូនដំណឹងអំពីប្រព័ន្ធតេឡេម៉ាទិចរថយន្តទៅឱ្យអនាគតម្ចាស់ ស្នើសុំការបញ្ជាក់ដោយមានហត្ថលេខាពីអនាគតម្ចាស់ថា ខ្លួនបានអានសេចក្តីជូនដំណឹងនោះ ហើយផ្តល់សំណៅនៃសេចក្តីជូនដំណឹងដែលបានចុះហត្ថលេខានោះជូនអនាគតម្ចាស់ ។ ការខកខានរបស់អ្នកចែកចាយក្នុងការអនុវត្តតាមបទប្បញ្ញត្តិនៃផ្នែកនេះត្រូវក្លាយជាដើមហេតុនៃការចាត់វិធានការរបស់អាជ្ញាធរដែលចេញអាជ្ញាបណ្ណទាក់ទងនឹងអាជ្ញាបណ្ណរបស់អ្នកចែកចាយ ដែលរាប់បញ្ចូលរហូតដល់ការដកហូតផងដែរ យោងតាមមាត្រា 59 នៃជំពូកទី 140 ។

ផ្នែកទី 5. ផ្នែកទី 6 នៃជំពូកទី 93K ត្រូវបានធ្វើវិសោធនកម្មដោយបន្ថែមនៅចុងបញ្ចប់នៃផ្នែកនេះដូចខាងក្រោម —

(e) បើទោះបីជាផ្នែករង (b) និង (c) រាល់ម្ចាស់ ឬយានដ្ឋានជួសជុលឯករាជ្យដែលទទួលបានការអនុញ្ញាតពីម្ចាស់ដែលត្រូវបានបដិសេធនូវសិទ្ធិចូលប្រើទិន្នន័យមេកានិចដោយការរំលោភលើផ្នែករង (d) (1) ឬ (f) នៃផ្នែកទី 2 អាចផ្តើមបណ្តឹងរដ្ឋប្បវេណីដែលស្វែងរកដំណោះស្រាយតាមច្បាប់ រួមទាំងរាល់សំណងដែលត្រូវបានអនុញ្ញាតដោយជំពូកទី 93A ។ រាល់ការបដិសេធលើសិទ្ធិចូលប្រើដោយការបំពានលើផ្នែករងនោះនឹងត្រូវទទួលរងសំណងការខូចខាតជាទឹកប្រាក់ចំនួន $10,000 ឬចំនួនមួយណាដែលធំជាងនេះ ។

# 2

## សំណួរទី 2 ៖ ច្បាប់ដែលបានស្នើឡើងដោយបដ្ឋនាលិខិតផ្តួចផ្តើម

# ការបោះឆ្នោតទៅតាមលំដាប់នៃជម្រើស

*តើអ្នកយល់ព្រមចំពោះច្បាប់ដែលបានសង្ខេបខាងក្រោមដែលក្នុងនោះការបោះឆ្នោតប្រឆាំងត្រូវបានទទួលយកដោយព្រឹទ្ធសភា ឬសភាតំណាងរាស្ត្រនៅថ្ងៃ ឬមុនថ្ងៃទី 5 ខែឧសភា ឆ្នាំ 2020 ដែរឬទេ ?*

**សេចក្តីសង្ខេប ▶**

តាមដែលច្បាប់តម្រូវ សេចក្តីសង្ខេបត្រូវបានសរសេរដោយអគ្គមេធាវីរបស់រដ្ឋ ។

ច្បាប់ដែលបានស្នើឡើងនេះនឹងអនុវត្តប្រព័ន្ធបោះឆ្នោតមួយដែលគេស្គាល់ថាជា “ការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់” ដែលអ្នកបោះឆ្នោតចាត់ថ្នាក់បេក្ខជនម្នាក់ ឬច្រើនតាមលំដាប់អាទិភាព ។ ការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់នឹងត្រូវប្រើក្នុងការបោះឆ្នោតបឋម និងការបោះឆ្នោតសកលសម្រាប់មុខតំណែងទូទាំងរដ្ឋ Massachusetts មុខតំណែងនីតិប្បញ្ញត្តិរដ្ឋ មុខតំណែងសភាសហព័ន្ធ និងមុខតំណែងមួយចំនួនទៀតដែលចាប់ផ្តើមនៅឆ្នាំ 2022 ។ ការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់នឹងមិនត្រូវបានប្រើក្នុងការបោះឆ្នោតជ្រើសរើសប្រធានាធិបតី ស្នងការខោនធី ឬសមាជិកគណៈកម្មាធិការមណ្ឌលសិក្សាធិការក្នុងតំបន់ទេ ។

យោងតាមច្បាប់ដែលបានស្នើឡើងនេះ ការរាប់សន្លឹកឆ្នោតនឹងធ្វើឡើងជាជុំបន្តបន្ទាប់ ។ ក្នុងជុំទីមួយ ប្រសិនបើបេក្ខជនម្នាក់ទទួលបានសំឡេងគាំទ្រលើសពី 50 ភាគរយនៃសំឡេងឆ្នោតចំណាត់ថ្នាក់ទីមួយ បេក្ខជននោះនឹងត្រូវប្រកាសថាជាអ្នកឈ្នះ ហើយមិនចាំបាច់មានការបោះឆ្នោតនៅជុំផ្សេងទៀតទេ ។ ប្រសិនបើគ្មានបេក្ខជនណាទទួលបានសំឡេងគាំទ្រលើសពី 50 ភាគរយនៃសំឡេងឆ្នោតចំណាត់ថ្នាក់ទីមួយ នោះបេក្ខជនម្នាក់ ឬបេក្ខជនច្រើននាក់ដែលទទួលបានសំឡេងគាំទ្រតិចជាងគេនឹងត្រូវបានជម្រុះចោល ហើយនៅជុំបន្ទាប់ការបោះឆ្នោតនីមួយៗសម្រាប់បេក្ខជនដែលបានជម្រុះចោលនឹងត្រូវរាប់បញ្ចូលទៅបេក្ខជនបន្ទាប់ជាប់លំដាប់ថ្នាក់ខ្ពស់ជាងគេលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោត ។ អាស្រ័យលើចំនួនបេក្ខជន ការរាប់សន្លឹកឆ្នោតជុំបន្ថែមអាចធ្វើឡើងដោយបេក្ខជនចំណាត់ថ្នាក់ចុងក្រោយម្នាក់ ឬច្រើននាក់នៅក្នុងជុំនីមួយៗត្រូវបានជម្រុះចោល ហើយការបោះឆ្នោតសម្រាប់បេក្ខជនដែលបានជម្រុះចោលនឹងទៅជម្រើសបន្ទាប់របស់អ្នកបោះឆ្នោតក្នុងចំណោមបេក្ខជនដែលនៅសល់ ។ លទ្ធផលស្មើសម្រាប់ចំណាត់ថ្នាក់ចុងក្រោយក្នុងជុំណាមួយនឹងត្រូវបានបែងចែកដោយប្រៀបធៀបសំឡេងគាំទ្ររបស់បេក្ខជនដែលទទួលបានលទ្ធផលស្មើក្នុងជុំមុន ។ នៅទីបំផុតបេក្ខជនក្នុងចំណោមបេក្ខជនដែលនៅសល់ដែលជាបេក្ខជនអាទិភាពរបស់អ្នកបោះឆ្នោតភាគច្រើននឹងត្រូវបានប្រកាសថាជាអ្នកឈ្នះ ។

ការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់នឹងត្រូវបានប្រើតែនៅក្នុងការប្រកួតប្រជែងដែលបេក្ខជនតែម្នាក់គត់នឹងត្រូវបានប្រកាសថាជាអ្នកឈ្នះ ហើយមិនមែននៅក្នុងការប្រកួតប្រជែងដែលជ្រើសរើសបេក្ខជនលើសពីម្នាក់ឡើយ ។

យោងតាមច្បាប់ដែលបានស្នើឡើងនេះ ប្រសិនបើគ្មានបេក្ខជនណាទទួលបានសំឡេងគាំទ្រច្រើនលើសពី 50 ភាគរយនៃសំឡេងឆ្នោតចំណាត់ថ្នាក់ទីមួយនៅក្នុងជុំទីមួយ នោះជុំនៃការរាប់សន្លឹកឆ្នោតដែលចាំបាច់សម្រាប់ការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់នឹងត្រូវធ្វើឡើងនៅមជ្ឈមណ្ឌលរាប់សន្លឹកឆ្នោត ។ នៅមជ្ឈមណ្ឌលនេះ ចំណាត់ថ្នាក់របស់អ្នកបោះឆ្នោតនឹងត្រូវកត់បញ្ចូលទៅក្នុងកុំព្យូទ័រដែលបន្ទាប់មកនឹងប្រើដើម្បីគណនាលទ្ធផលនៃជុំនីមួយៗនៃដំណើរការរាប់សន្លឹកឆ្នោត ។ ច្បាប់ដែលបានស្នើឡើងនេះចែងថា បេក្ខជននៅក្នុងការបោះឆ្នោតទូទាំងរដ្ឋ ឬការបោះឆ្នោតរបស់មណ្ឌលនឹងមានរយៈពេលយ៉ាងតិចបីថ្ងៃ ដើម្បីស្នើសុំការរាប់ឡើងវិញ ។

រដ្ឋលេខាធិការនឹង តម្រូវឲ្យ ចេញបទបញ្ជា ដើម្បីអនុវត្តច្បាប់ដែលបានស្នើឡើងនេះ និងធ្វើយុទ្ធនាការអប់រំអ្នកបោះឆ្នោតអំពីដំណើរការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់ ។ ច្បាប់ដែលបានស្នើឡើងនេះនឹងចូលជាធរមាននៅថ្ងៃទី 1 ខែមករា ឆ្នាំ 2022 ។

---

**អ្វីដែលសន្លឹកឆ្នោតរបស់អ្នកនឹងធ្វើ ▶**

តាមដែលច្បាប់តម្រូវ សេចក្តីថ្លែងការណ៍ដែលរៀបរាប់អំពីផលប៉ះពាល់នៃការបោះឆ្នោត “គាំទ្រ” ឬ “ប្រឆាំង” ត្រូវបានសរសេររួមគ្នាដោយអគ្គមេធាវីរបស់រដ្ឋ និងលេខាធិការរដ្ឋសហធន ។

***ការបោះឆ្នោតគាំទ្រ*** នឹងបង្កើតប្រព័ន្ធបោះឆ្នោតទៅតាមលំដាប់នៃជម្រើសដែលអ្នកបោះឆ្នោតនឹងមានជម្រើសក្នុងការចាត់ថ្នាក់បេក្ខជនតាមលំដាប់អាទិភាព និងការបោះឆ្នោតនឹងត្រូវរាប់តាមជុំ ដោយជម្រុះបេក្ខជនដែលមានសំឡេងឆ្នោតគាំទ្រតិចបំផុតរហូតដល់បេក្ខជនម្នាក់បានទទួលសំឡេងគាំទ្រច្រើនជាងគេ ។

***ការបោះឆ្នោតប្រឆាំង*** នឹងមិនផ្លាស់ប្តូរច្បាប់គ្រប់គ្រងការបោះឆ្នោត និងរបៀបរាប់សន្លឹកឆ្នោតទេ ។

---

**សេចក្តីថ្លែងការណ៍អំពីផលវិបាកនៃសារពើពន្ធ ▶**

តាមដែលច្បាប់តម្រូវ សេចក្តីថ្លែងការណ៍អំពីផលវិបាកនៃសារពើពន្ធត្រូវបានសរសេរដោយការិយាល័យប្រតិបត្តិផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ។

វិធានការនេះនឹងទំនងជាតម្រូវឱ្យមានការចំណាយផ្នែកអនុវត្តសម្រាប់មន្ត្រីរៀបចំការបោះឆ្នោតរបស់រដ្ឋ និងរបស់សាលាក្រុង ប៉ុន្តែដោយសារច្បាប់ដែលបានស្នើឡើងនេះនឹងអនុវត្តតែចំពោះការបោះឆ្នោត និងការបោះឆ្នោតបឋមធ្វើឡើងនៅ ឬបន្ទាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2022 គេមិនដឹងពីផលវិបាកនៃសារពើពន្ធលើវិធានការដែលបានស្នើឡើងសម្រាប់ហិរញ្ញវត្ថុរបស់រដ្ឋ និងសាលាក្រុងទេ ។

# សំណួរទី 2៖ ច្បាប់ដែលបានស្នើឡើងដោយបដ្ឋនាលិខិតផ្តួចផ្តើម

**សេចក្តីអះអាង ▶**

តាមដែលច្បាប់តម្រូវ សេចក្តីអះអាងដែលមាន 150 ពាក្យត្រូវបានសរសេរដោយអ្នកគាំទ្រ និងអ្នកប្រឆាំងសំណួរនីមួយៗ និងបង្ហាញអំពីមតិយោបល់របស់ពួកគេ ។ រដ្ឋសហធន Massachusetts មិនយល់ព្រមចំពោះសេចក្តីអះអាងទាំងនេះទេ ហើយមិនបញ្ជាក់ភាពពិត ឬភាពត្រឹមត្រូវនៃសេចក្តីថ្លែងការណ៍ណាមួយដែលបានធ្វើឡើងនៅក្នុងសេចក្តីអះអាងទាំងនេះឡើយ ។ ឈ្មោះរបស់បុគ្គល និងអង្គភាពនានាដែលបានសរសេរសេចក្តីអះអាងនីមួយៗ និងមតិយោបល់ណាមួយដែលសរសេរជាលាយលក្ខណ៍អក្សរដោយអ្នកដទៃទៀតអំពីសេចក្តីអះអាងនីមួយៗនោះ មាននៅក្នុងឯកសារនៅការិយាល័យលេខាធិការរដ្ឋសហធន ។

***ការគាំទ្រ ៖*** ការបោះឆ្នោតគាំទ្រគឺអនុម័តការបោះឆ្នោតទៅតាមលំដាប់នៃជម្រើស កំណែទម្រង់រួមដែលធ្វើឲ្យអំណាចកាន់តែច្រើនធ្លាក់នៅក្នុងដៃរបស់ម្ចាស់ឆ្នោត ។

ការបោះឆ្នោតទៅតាមលំដាប់នៃជម្រើសដោះស្រាយបញ្ហាបីយ៉ាង ៖

- ក្រុមអ្នកមានលុយច្រើន និងក្រុមផលប្រយោជន៍ពិសេសដែលពុករលួយមានការគ្រប់គ្រងច្រើនពេកលើលទ្ធិប្រជាធិបតេយ្យរបស់យើង
- ក្រុមអ្នកនយោបាយអាចឈ្នះដោយសំឡេងភាគច្រើន ហើយអ្នកឯករាជ្យត្រូវបានបិទមាត់
- អ្នកនយោបាយកំពុងហែកហួរយើងដោយរារាំងមិនឲ្យមានដំណោះស្រាយចំពោះបញ្ហាប្រឈមធំៗ

វាដំណើរការដោយផ្តល់ឱ្យអ្នកបោះឆ្នោតនូវជម្រើសដើម្បីចាត់ថ្នាក់បេក្ខជនតាមលំដាប់នៃអាទិភាព ។ អ្នកអាចបោះឆ្នោតឱ្យបេក្ខជនតែម្នាក់គត់ដូចដែលអ្នកមានជានិច្ច ឬអ្នកអាចជ្រើសរើសជម្រើសទីមួយ ទីពីរ និងទីបីរបស់អ្នក ។ ប្រសិនបើបេក្ខជនដែលអ្នកគាំទ្រមិនឈ្នះឆ្នោត សន្លឹកឆ្នោតរបស់អ្នកត្រូវបានរាប់ភ្លាមសម្រាប់ជម្រើសទីពីររបស់អ្នក ដូច្នេះបេក្ខជនត្រូវតែចូលរួមប្រកួតប្រជែងរាល់ការបោះឆ្នោតនីមួយៗ ។ ការបោះឆ្នោតទៅតាមលំដាប់នៃជម្រើសធានាថាអ្នកឈ្នះទទួលបានសំឡេងគាំទ្រភាគច្រើន និងឆ្លុះបញ្ចាំងពីឆន្ទៈពិតប្រាកដរបស់ប្រជាជន ។

ការបោះឆ្នោតគាំទ្រផ្តល់ឱ្យអ្នកបោះឆ្នោតនូវសំឡេងឆ្នោតកាន់តែច្រើន ហើយនឹងជួយធ្វើឱ្យប្រជាធិបតេយ្យរបស់យើងកាន់តែរឹងមាំ ។

**Shauna Hamilton**
**Voter Choice for Massachusetts**
**44 Temple Place**
**Boston, MA 02111**
**617-906-8166**
**www.voterchoice2020.org**

***ប្រឆាំង៖*** អភិបាលប្រជាធិបតេយ្យចំនួនពីររូបបានច្រានចោលការបោះឆ្នោតទៅតាមលំដាប់នៃជម្រើស ពីព្រោះវាមានភាពច្របូកច្របល់ និងបានបដិសេធជម្រើសត្រឹមត្រូវរបស់អ្នកបោះឆ្នោត ។ លោកអភិបាលរដ្ឋខាងប្រជាធិបតេយ្យ Jerry Brown បានធ្វើជាសាក្សីក្នុងការបោះឆ្នោតជ្រើសរើសអភិបាលក្រុងមួយនៅទីក្រុង Oakland ដែលអ្នកឈ្នះបានឈ្នះជាមួយនឹងចំណាត់ថ្នាក់ទីប្រាំពីរ និងទីប្រាំបីរបស់អ្នកបោះឆ្នោត ។ លោក Brown អភិបាលរដ្ឋមានប្រសាសន៍ថា "ការបោះឆ្នោតទៅតាមលំដាប់នៃជម្រើសមានភាពស្មុគស្មាញ និងច្របូកច្របល់ខ្លាំង ។ ខ្ញុំជឿថា វានឹងដកហូតជម្រើសពិតប្រាកដរបស់អ្នកបោះឆ្នោត" ។ លោកអភិបាលខាងប្រជាធិបតេយ្យ Gavin Newsom បានមានប្រសាសន៍ថា ការបោះឆ្នោតទៅតាមលំដាប់នៃជម្រើស "ជារឿយៗនាំឱ្យមានភាពច្របូកច្របល់ដល់អ្នកបោះឆ្នោត ហើយមិនបានបំពេញតាមការសន្យាថាការបោះឆ្នោតទៅតាមលំដាប់នៃជម្រើសនាំទៅកលទ្ធិប្រជាធិបតេយ្យកាន់តែខ្លាំងនោះទេ" ។

សន្លឹកបោះឆ្នោតទៅតាមលំដាប់នៃជម្រើសបង្ខំឱ្យអ្នកបោះឆ្នោតស្មានបេក្ខជនដែលនឹងនៅតែឈរឈ្មោះនៅក្នុងការបោះឆ្នោតច្រើនជុំ ហើយធ្វើការបោះឆ្នោតទាំងងងឹតងងុល ។ បើគេស្មានខុស ហើយបោះឆ្នោតឲ្យបេក្ខជនដែលបានជម្រុះចោល សន្លឹកឆ្នោតរបស់គេមិនត្រូវបានរាប់បញ្ចូលក្នុងការបោះឆ្នោតចុងក្រោយឡើយ ។ អ្នកឈ្នះនឹងឈ្នះ "សំឡេងភាគច្រើន" ក្លែងក្លាយនៃសន្លឹកឆ្នោតដែលនៅសេសសល់ មិនមែនជាសំឡេងភាគច្រើនពិតប្រាកដនៃអ្នកបោះឆ្នោតទាំងអស់ដែលបានបោះឆ្នោតនៅក្នុងការបោះឆ្នោតនោះទេ ។

**Massachusetts Fiscal Alliance**
**18 Tremont St., Suite 527**
**Boston, MA 02108**
**617-553-4115**
**https://www.massfiscal.org**

### អត្ថបទទាំងស្រុងនៃសំណួរ

វាត្រូវអនុម័តដោយប្រជាពលរដ្ឋ និងដោយអាជ្ញាធររបស់ពួកគេ ៖

ច្បាប់ដើម្បីអនុវត្តការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់នៅក្នុងការបោះឆ្នោត

ផ្នែកទី 1. ផ្នែកទី 1 នៃជំពូកទី 50 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយការបញ្ចូលក្រោយនិយមន័យនៃពាក្យ "ការបោះឆ្នោតបឋម" និងមុននិយមន័យនៃពាក្យ "មន្ត្រីចុះបញ្ជី" នូវនិយមន័យខាងក្រោម៖ —

"ការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់" មានន័យថា ក្នុងករណីការបោះឆ្នោត និងការបោះឆ្នោតបឋមដែលសន្លឹកឆ្នោតត្រូវបានរៀបចំស្របតាមផ្នែកទី 43A នៃជំពូកទី 54 ជាវិធីសាស្ត្រក្នុងការបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលត្រូវបានពណ៌នាជាពិសេសនៅក្នុងផ្នែកទី 2A និងទី 2B នៃជំពូកទី 50 ។

ផ្នែកទី 2. ផ្នែកទី 2 នៃជំពូកទី 50 ដែលបានលើកឡើង ត្រូវបានធ្វើវិសោធនកម្មដោយការបន្ថែមប្រយោគខាងក្រោមទៅផ្នែកខាងចុងនៃផ្នែកដែលបានលើកឡើង៖—

ការកំណត់នូវអ្នកដែលទទួលសំឡេងឆ្នោតច្រើនជាងគេសម្រាប់មុខតំណែងមួយនៅក្នុងការបោះឆ្នោតបឋម ឬការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់នឹងត្រូវបានគ្រប់គ្រងដោយផ្នែកទី 2A និងទី 2B នៃជំពូកទី 50 ។

ផ្នែកទី 3. ជំពូកទី 50 ដែលបានលើកឡើងត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយការបញ្ចូលក្រោយផ្នែកទី 2 នូវផ្នែកទី 2A ខាងក្រោម៖—

ផ្នែកទី 2A. ដូចដែលបានប្រើនៅក្នុងផ្នែកនេះ និងផ្នែកទី 2B លើកលែងតែបរិបទមានការបញ្ជាក់ផ្សេងទៀត ពាក្យខាងក្រោមមានអត្ថន័យដូចតទៅ ៖

"អាទិភាពសកម្ម" មានន័យថាជាសំឡេងឆ្នោតដែលត្រូវបានដាក់ទៅឱ្យលំដាប់បន្តខ្ពស់ជាងគេលើសន្លឹកឆ្នោតបន្ត ។

"ការជម្រុះជាក្រុម" មានន័យថាជាការចាញ់ដំណាលគ្នារបស់បេក្ខជនច្រើននាក់ដោយសារមានចំណុចមួយក្នុងចំណោមចំណុចខាងក្រោមត្រូវបានអនុវត្តទាក់ទងនឹងបេក្ខជន ៖

(a) បេក្ខជនមិនអាចត្រូវបានបោះឆ្នោតជ្រើសរើសបាន ដោយសារចំនួនសរុបនៃ

**អត្ថបទទាំងស្រុងនៃសំណួរ (ត)**

សំឡេងអាទិភាពសកម្មរបស់បេក្ខជននៅក្នុងជុំនៃការរាប់សន្លឹកឆ្នោតដែលបោះទៅតាមការជ្រើសរើសតាមលំដាប់ថ្នាក់ បូកនឹងចំនួនសរុបនៃសន្លឹកឆ្នោតបន្តទាំងអស់ដែលអាចត្រូវផ្ទេរទៅឱ្យបេក្ខជននៅក្នុងជុំបន្ទាប់ពីបេក្ខជនដែលមានសំឡេងអាទិភាពសកម្មតិច ឬស្មើ គឺមិនគ្រប់ដើម្បីលើសបេក្ខជនដែលមានចំនួនសរុបនៃសំឡេងអាទិភាពសកម្មខ្ពស់ជាងបន្ទាប់នៅក្នុងជុំ ឬ

(b) បេក្ខជនមានចំនួនសរុបនៃសំឡេងអាទិភាពសកម្មទាបជាងបេក្ខជនដែលបានពណ៌នាក្នុងកថាខណ្ឌរង (a) ។

"សន្លឹកឆ្នោតបញ្ចប់" មានន័យថាជាសន្លឹកឆ្នោតដែលមិនដាក់លំដាប់បេក្ខជនបន្តណាទាំងអស់ មានការបោះឆ្នោតលើសកំណត់ នៅលំដាប់បន្តខ្ពស់ជាងគេ ឬមានលំដាប់ដែលរំលងបន្តគ្នាពីរ ឬច្រើន មុនដល់លំដាប់បន្តខ្ពស់ជាងគេ ។

"សន្លឹកឆ្នោតបន្ត" មានន័យថាជាសន្លឹកឆ្នោតដែលមិនមែនជាសន្លឹកឆ្នោតបញ្ចប់ ។

"បេក្ខជនបន្ត" មានន័យថាជាបេក្ខជនដែលមិនបានចាញ់ ។

"លំដាប់បន្តខ្ពស់ជាងគេ" មានន័យថា បេក្ខជនបន្តដែលមានលំដាប់ខ្ពស់ជាងគេនៅលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោត ។

"បេក្ខជននៅកន្លែងចុងក្រោយ" មានន័យថា (a) បេក្ខជនដែលមានចំនួនសរុបនៃសំឡេងអាទិភាពសកម្មទាបជាងគេនៅក្នុងជុំនៃការរាប់សន្លឹកឆ្នោតដែលបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់ ឬ (b) បេក្ខជនដែលចាញ់នៅក្នុងការជម្រុះជាក្រុម ។

"ការបោះឆ្នោតលើសកំណត់" មានន័យថាជាកាលៈទេសៈដែលអ្នកបោះឆ្នោតដាក់បេក្ខជនលើសពីម្នាក់នៅលំដាប់ថ្នាក់តែមួយ ។

"លំដាប់ថ្នាក់" មានន័យថាជាលេខដែលបានដាក់នៅលើសន្លឹកឆ្នោតដោយអ្នកបោះឆ្នោតចំពោះបេក្ខជន ដើម្បីបង្ហាញពីអាទិភាពរបស់អ្នកបោះឆ្នោតចំពោះបេក្ខជននោះ ។ លំដាប់ថ្នាក់លេខមួយ គឺជាលំដាប់ថ្នាក់ដែលខ្ពស់ជាងគេ លំដាប់ថ្នាក់លេខពីរ គឺជាលំដាប់ថ្នាក់ខ្ពស់ជាងគេបន្ទាប់ និងបន្តដូច្នេះបន្តទៀត ។

"ជុំ" មានន័យថាលំដាប់ថ្នាក់បន្តបន្ទាប់នៃជំហានរាប់សន្លឹកឆ្នោត ដែលត្រូវបានបង្កើតឡើងនៅក្នុងផ្នែករងទី 1 នៃផ្នែកទី 2B ។

"លំដាប់ថ្នាក់ដែលរំលង" មានន័យថាជាលំដាប់ថ្នាក់ដែលមិនត្រូវបានដាក់នៅលើសន្លឹកឆ្នោតដោយអ្នកបោះឆ្នោតចំពោះបេក្ខជនណាមួយ ក្នុងពេលដែលលំដាប់ថ្នាក់ទាបជាងត្រូវបានដាក់លើសន្លឹកឆ្នោតដោយអ្នកបោះឆ្នោតចំពោះបេក្ខជនម្នាក់ ។

ផ្នែកទី 4. ជំពូកទី 50 ដែលបានលើកឡើង ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយការបញ្ចូលក្រោយផ្នែកទី 2A នូវផ្នែកទី 2B ខាងក្រោម ៖—

ផ្នែកទី 2B. ចំណុចខាងក្រោមអនុវត្តសម្រាប់ការកំណត់លទ្ធផលនៃការបោះឆ្នោតបឋម និងការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់ ។

1. លើកលែងតែករណីដែលមានចែងក្នុងផ្នែករងទី 2 ខាងក្រោមទាក់ទងនឹងសំឡេងស្មើគ្នា នីតិវិធីខាងក្រោមត្រូវបានប្រើ ដើម្បីកំណត់អ្នកដែលទទួលបានសំឡេងឆ្នោតខ្ពស់ជាងគេសម្រាប់គោលបំណងនៃផ្នែកទី 2 នៃជំពូកទី 50 នៅក្នុងការបោះឆ្នោត ឬការបោះឆ្នោតបឋមសម្រាប់ការិយាល័យណាដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់ ។ ការរាប់សន្លឹកឆ្នោតត្រូវតែធ្វើឡើងជាជុំ ។ ក្នុងមួយជុំ ចំនួននៃសំឡេងអាទិភាពសកម្មសម្រាប់បេក្ខជនបន្តនីមួយៗត្រូវតែបានរាប់ ។ សន្លឹកឆ្នោតបន្តមួយរាប់ជាសំឡេងអាទិភាពសកម្មមួយសម្រាប់បេក្ខជនដែលមានលំដាប់ថ្នាក់បន្តខ្ពស់ជាងគេរបស់វាសម្រាប់ជុំនោះ ។ សន្លឹកឆ្នោតបញ្ចប់មិនត្រូវបានរាប់សម្រាប់បេក្ខជនបន្តណាមួយទេ ។ ជុំនឹងបញ្ចប់ដោយចំណុចណាមួយខាងក្រោម ៖

A. ត្រឹមជុំទីមួយប៉ុណ្ណោះ បើសិនជាបេក្ខជនម្នាក់ទទួលបានច្រើនជាងហាសិបភាគរយនៃសំឡេងអាទិភាពសកម្មទាំងអស់ដែលត្រូវបានរាប់នៅក្នុងជុំទីមួយសម្រាប់បេក្ខជនទាំងអស់ បេក្ខជននោះត្រូវបានកំណត់ថាជាអ្នកដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេ ហើយការរាប់សន្លឹកឆ្នោតនឹងត្រូវបញ្ចប់ ។

B. ពុំនោះទេ បើសិនជាមានបេក្ខជនបន្តលើសពីពីរនាក់ បេក្ខជននៅកន្លែងចុងក្រោយត្រូវចាញ់ ឬបណ្តាបេក្ខជននៅកន្លែងចុងក្រោយត្រូវចាញ់នៅក្នុងការជម្រុះជាក្រុម ហើយជុំថ្មីនឹងចាប់ផ្តើម ។

C. បើសិនជាមានបេក្ខជនបន្តពីរនាក់ ឬតិចជាងពីរនាក់ នោះបេក្ខជនដែលមានសំឡេងអាទិភាពសកម្មច្រើនជាងគេត្រូវបានកំណត់ថាជាអ្នកដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេ ហើយការរាប់សន្លឹកឆ្នោតនឹងត្រូវបញ្ចប់ ។

2. បើសិនជាបេក្ខជននៅកន្លែងចុងក្រោយពីនាក់ ឬច្រើននាក់មានសំឡេងស្មើគ្នា ហើយការជម្រុះជាក្រុមមិនត្រូវបានអនុវត្ត នោះអ្នកដែលមានសំឡេងអាទិភាពសកម្មតិចជាងគេនៅក្នុងជុំមុននឹងត្រូវចាញ់ ។ បើសិនជាមានបេក្ខជនពីរនាក់ ឬច្រើននាក់មានសំឡេងស្មើគ្នានៅក្នុងជុំមុន នោះការមានសំឡេងស្មើគ្នាលើកទីពីរនឹងត្រូវសម្រេចដោយយោងដូចគ្នាទៅនឹងការឈរឈ្មោះរបស់បេក្ខជននៅក្នុងជុំមុនបន្ទាប់ បើគិតពីសំឡេងអាទិភាពសកម្ម ។ គោលការណ៍នេះត្រូវបានអនុវត្តជាបន្តបន្ទាប់ច្រើនដងតាមដែលចាំបាច់ ការមានសំឡេងស្មើគ្នាដែលត្រូវបានបង្ហាញនៅជុំមុនណាមួយត្រូវបានសម្រេចដោយការយោងទៅលើការឈរឈ្មោះរបស់បេក្ខជននៅក្នុងជុំដែលនៅមុនជុំដែលមានសំឡេងស្មើគ្នានោះ ។

3. ក្នុងគោលបំណងដើម្បីកំណត់ភាគរយនៃសំឡេងឆ្នោតទាំងមូលនៅក្នុងរដ្ឋសហធនសម្រាប់ការិយាល័យមួយដែលត្រូវបំពេញដោយអ្នកបោះឆ្នោតទាំងអស់នៃរដ្ឋសហធន ដូចមានចែងក្នុងនិយមន័យនៃ “គណបក្សនយោបាយ” នៅក្នុងផ្នែកទី 1 នៃជំពូកទី 50 សំឡេងឆ្នោតដែលបោះឱ្យបេក្ខជនរបស់គណបក្សមួយសម្រាប់ការិយាល័យមួយដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់ គឺជាចំនួននៃសំឡេងអាទិភាពសកម្មដែលត្រូវបានបញ្ចូលឱ្យបេក្ខជននោះបន្ទាប់ពីការរាប់លើកដំបូងក្នុងជុំទីមួយដែលបានពណ៌នាក្នុងផ្នែកទី 1 ខាងលើ ។

ផ្នែកទី 5. ផ្នែកទី 1 នៃជំពូកទី 53 នៃច្បាប់ទូទៅត្រូវបានធ្វើវិសោធនកម្មដោយលុបចោលនូវប្រយោគទីពីរ ហើយដាក់បញ្ចូលជំនួសវិញនូវប្រយោគខាងក្រោម ៖—

គណបក្សដែលធ្វើការតែងតាំងអ្នកឈរឈ្មោះម្នាក់ ឬច្រើននាក់ នឹងមានសិទ្ធិមានឈ្មោះបេក្ខជននីមួយៗរបស់ខ្លួននៅលើសន្លឹកឆ្នោតដែលត្រូវប្រើនៅពេលបោះឆ្នោតជាបន្ត ប៉ុន្តែ លើកលែងតែការតែងតាំងត្រូវបានធ្វើឡើងនៅក្នុងការបោះឆ្នោតបឋមដែលសន្លឹកឆ្នោតត្រូវបានគេរៀបចំស្របតាមផ្នែក

## អត្ថបទទាំងស្រុងនៃសំណួរ (ត)

ទី 43A នៃជំពូកទី 54 ឬនៅក្នុងការប្រជុំគណបក្សច្រើនដងដែលធ្វើឡើង នៅក្នុងមណ្ឌលបោះឆ្នោតច្រើនជាងមួយ ឬនៅតំបន់បោះឆ្នោត ឬក្រុមនៃតំបន់បោះឆ្នោតច្រើនជាងមួយ ដោយការបោះឆ្នោតបែបពហុផ្ទាល់ នោះវិញ្ញាបនបត្រនៃការតែងតាំងត្រូវតែបានដាក់ដូចមានចែងក្នុងផ្នែកទីប្រាំ ។

ផ្នែកទី 6. ផ្នែកទី 2 នៃជំពូកទី 53 ដែលបានលើកឡើង ត្រូវបានធ្វើវិសោធនកម្ម ដោយលុបចោលនូវប្រយោគទីពីរ និងដាក់បញ្ចូលជំនួសវិញនូវប្រយោគពីរខាងក្រោម ៖—

រាល់ការតែងតាំង និងការបោះឆ្នោតនៅក្នុងការបោះឆ្នោតបឋមដែលសន្លឹកឆ្នោតត្រូវបានរៀបចំស្របតាមផ្នែកទី 43A នៃជំពូកទី 54 ត្រូវប្រើការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់ដើម្បីកំណត់បុគ្គលដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេ ។ រាល់ការតែងតាំង និងការបោះឆ្នោតនៅក្នុងការប្រជុំបក្សត្រូវធ្វើឡើងដោយការបោះឆ្នោតបែបពហុផ្ទាល់ ។

ផ្នែកទី 7. ជំពូកទី 54 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយបញ្ចូលក្រោយផ្នែកទី 43A នូវផ្នែក 43B ខាងក្រោម ៖ —

ផ្នែកទី 43B. រាល់ការបោះឆ្នោត និងការបោះឆ្នោតបឋមទាំងអស់ដែលសន្លឹកឆ្នោតត្រូវបានរៀបចំស្របតាមផ្នែកទី 43A ហើយដែលមានតែមនុស្សម្នាក់ដែលត្រូវបានបោះឆ្នោតជ្រើសរើសសម្រាប់គោលបំណងនៃផ្នែកទី 2 នៃជំពូកទី 50 ត្រូវប្រើការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់ ដើម្បីកំណត់អ្នកដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេសម្រាប់មុខតំណែង លើកលែងតែចំណុចខាងក្រោម ៖

(a) ការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់មិនត្រូវប្រើសម្រាប់ការបោះឆ្នោតជ្រើសរើសអ្នកបោះឆ្នោតប្រធានាធិបតីទេ ។

(b) ការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់មិនត្រូវប្រើសម្រាប់មុខតំណែងដែលបានពណ៌នា និងត្រូវបានជ្រើសរើសស្របតាមផ្នែកទី 4 នៃជំពូកទី 34 និងផ្នែកទី 14E នៃជំពូកទី 71 ទេ ។

(c) ការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់មិនត្រូវប្រើនៅក្នុងការបោះឆ្នោតបឋម ឬការបោះឆ្នោតពិសេសសម្រាប់ការិយាល័យដែលមានបេក្ខជនពីររូប ឬតិចជាងទេ ដូចដែលបានរាយការណ៍ដោយរដ្ឋលេខាធិការយោងតាមផ្នែកទី 49 នៃជំពូកទី 54 ទេ ។

ផ្នែកទី 8. ផ្នែកទី 77 នៃជំពូកទី 54 នៃច្បាប់ទូទៅត្រូវបានធ្វើវិសោធនកម្មដោយលុបចោលនូវឃ្លា “គូសសញ្ញាខ្វែង (X) នៅក្នុងការ៉េនៅខាងស្តាំឈ្មោះបេក្ខជននីមួយៗសម្រាប់អ្នកដែលគាត់មានបំណងបោះឆ្នោតឱ្យ” ហើយបញ្ចូលជំនួសវិញនូវឃ្លាខាងក្រោម ៖ “គូសសម្គាល់សន្លឹកឆ្នោតតាមរបៀបដែលរដ្ឋលេខាធិការបានបង្គាប់តាមបទបញ្ញត្តិ” ។

ផ្នែកទី 9. ផ្នែកទី 78 នៃជំពូកទី 54 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មដោយលុបចោលនូវឃ្លា “គូសសញ្ញាខ្វែង (X) នៅក្នុងការ៉េនៅខាងស្តាំឈ្មោះនៃក្រុមបេក្ខជនឈរឈ្មោះសម្រាប់ការិយាល័យ ដែលគាត់ចង់បោះឆ្នោតឱ្យ” នៅក្នុងប្រយោគទីបី និងបញ្ចូលជំនួសនូវឃ្លាខាងក្រោម ៖ “គូសសម្គាល់សន្លឹកឆ្នោតតាមរបៀបដែលរដ្ឋលេខាធិការបានបង្គាប់តាមបទបញ្ញត្តិ” ។

ផ្នែកទី 10. ជំពូកទី 54 នៃច្បាប់ទូទៅ ត្រូវបានធ្វើវិសោធនកម្មបន្ថែមដោយបញ្ចូលក្រោយផ្នែកទី 105A នូវផ្នែក 105B ខាងក្រោម ៖ —

ផ្នែកទី 105B. សម្រាប់ការបោះឆ្នោត ឬការបោះឆ្នោតបឋមទាំងអស់ដែលប្រើការបោះឆ្នោតជ្រើសរើសតាមលំដាប់ស្របតាមផ្នែកទី 43B រដ្ឋលេខាធិការនឹងបង្កើតកន្លែងរាប់សន្លឹកឆ្នោតកណ្តាលសម្រាប់គោលបំណងនៃការរាប់សំឡេងអាទិភាពសកម្មបន្ទាប់ពីជុំដំបូងនៃការរាប់ត្រូវបានបញ្ចប់ស្របតាមផ្នែកទី 33H និងទី 105 ។

ក្នុងករណីការបោះឆ្នោត ឬការបោះឆ្នោតបឋមដែលអ្នកដែលទទួលបានសំឡេងឆ្នោតច្រើនជាងគេមិនត្រូវបានកំណត់ក្រោមកថាខណ្ឌ 1A នៃផ្នែកទី 2B នៃជំពូកទី 50 ហើយទោះបីជាមានច្បាប់ទូទៅ ពិសេស ឬច្បាប់មូលដ្ឋានណាមួយក៏ដោយដែលផ្ទុយ ក៏កំណត់ត្រាសន្លឹកឆ្នោតទាំងអស់ ដែលបានបោះនៅក្នុងការបោះឆ្នោត ឬការបោះឆ្នោតបឋមនឹងត្រូវប្រគល់ទៅកន្លែងរាប់សន្លឹកឆ្នោតកណ្តាលដែលត្រូវបានបង្កើតឡើងតាមផ្នែកនេះដូចខាងក្រោម ៖

A. ចំពោះសន្លឹកឆ្នោតដែលបានរាប់ស្របតាមផ្នែក 33H ស្មៀនសាលាក្រុង ឬក្រុងត្រូវប្រគល់កំណត់ត្រាសន្លឹកឆ្នោតដែលបានបោះ មានន័យថាកំណត់ត្រាទិន្នន័យនៃលំដាប់ថ្នាក់នីមួយៗដែលបានដាក់សម្គាល់របស់សន្លឹកឆ្នោតនីមួយៗដែលបានបោះ មិនថាជាអេឡិចត្រូនិច ក្រដាស ឬទម្រង់ផ្សេងទៀតឡើយ តាមមធ្យោបាយដែលមានសុវត្ថិភាពដូចដែលបានបង្កើត និងអនុម័តដោយរដ្ឋលេខាធិការតាមបទប្បញ្ញត្តិ ឬបើមិនដូច្នេះទេដូចដែលបានពណ៌នានៅក្នុងផ្នែកទី 105A ។ ចំពោះសន្លឹកឆ្នោតដែលមិនត្រូវបានរាប់បញ្ចូលក្នុងកំណត់ត្រាសន្លឹកឆ្នោតដែលបានបោះ ដូចជាសន្លឹកឆ្នោតដែលត្រូវបានបដិសេធដោយកុំព្យូទ័រ ឬអង្គភាពរាប់សន្លឹកឆ្នោត ឬសន្លឹកឆ្នោតដែលត្រូវបានបំផ្លាញ ដើម្បីមិនអាចបញ្ចូលទៅក្នុងកុំព្យូទ័រ ឬអង្គភាពរាប់សន្លឹកឆ្នោត សន្លឹកឆ្នោតនឹងត្រូវបានបញ្ចូលទៅក្នុងកំណត់ត្រាសន្លឹកឆ្នោតដែលបានបោះតាមលក្ខណៈមួយដែលអាចសង្កេតបានដោយអ្នកត្រួតពិនិត្យពីរនាក់នៃគណបក្សនយោបាយផ្សេងគ្នា ដើម្បីទទួលបាននូវកំណត់ត្រាសន្លឹកឆ្នោតដែលបានបោះពេញលេញ ។

B. ចំពោះសន្លឹកឆ្នោតដែលបានរាប់ស្របតាមផ្នែកទី 105 ទោះបីមានការតម្រូវឱ្យដាក់សម្ភារៈបោះឆ្នោតទាំងអស់នៅក្នុងកន្លែងដែលចាក់សោក៏ដោយ ស្មៀនសាលាក្រុងត្រូវប្រគល់សន្លឹកឆ្នោតដែលបានបោះទាំងអស់រួមទាំងសន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមានតាមមធ្យោបាយសុវត្ថិភាពដូចដែលបានបង្កើត និងអនុម័តដោយរដ្ឋលេខាធិការតាមបទប្បញ្ញត្តិ ឬមិនដូច្នោះទេ ដូចបានពណ៌នានៅក្នុងផ្នែកទី 105A ។

សម្រាប់កន្លែងរាប់សន្លឹកឆ្នោតកណ្តាលដែលត្រូវបានកំណត់ក្នុងផ្នែកនេះ រដ្ឋលេខាធិការត្រូវតែងតាំងមន្ត្រីបោះឆ្នោតដូចខាងក្រោម៖ ប្រធានមណ្ឌលបោះឆ្នោត អនុប្រធានមណ្ឌលបោះឆ្នោត ស្មៀន និងស្មៀនរង និងជាអ្នកត្រួតពិនិត្យ និងអ្នកត្រួតពិនិត្យរងច្រើននាក់ដូចដែលរដ្ឋលេខាធិការកំណត់ថាចាំបាច់ ។

ប្រធាននៃគណៈកម្មាធិការរដ្ឋនីមួយៗអាចតែងតាំងជាលាយលក្ខណ៍អក្សរនូវបុគ្គលដែលប្រធានចាត់ទុកថាជាអ្នកជំនាញខាងកុំព្យូទ័រ ដើម្បីពិនិត្យតាមដាន

**អត្ថបទទាំងស្រុងនៃសំណួរ** (ត)

ការរាប់សន្លឹកឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិចនៅកន្លែងរាប់សន្លឹកឆ្នោតកណ្តាល ។ អ្នកជំនាញត្រូវបានជ្រើសតាំងដោយមន្ត្រីអធិបតីឱ្យទៅកាន់ទីតាំងមួយនៅក្នុងមណ្ឌលដែលអាចឱ្យអ្នកជំនាញសង្កេតមើលរាល់ប្រតិបត្តិការទាំងអស់ ។

រដ្ឋលេខាធិការត្រូវតែជាមន្ត្រីអធិបតីនៅកន្លែងរាប់សន្លឹកឆ្នោតកណ្តាល និងត្រូវប្រគល់ឱ្យមន្ត្រីបោះឆ្នោតនូវភារកិច្ចនានាដើម្បីធានានូវភាពត្រឹមត្រូវ និងពេញលេញនៃការរាប់សន្លឹកឆ្នោតស្របតាមវិធាន និងបទបញ្ញត្តិសម្រាប់ប្រតិបត្តិការមណ្ឌលរាប់សន្លឹកឆ្នោតដែលត្រូវបានប្រកាសឱ្យប្រើដោយការិយាល័យរដ្ឋលេខាធិការ ។

តាមរយៈមធ្យោបាយផ្សេងៗដែលបង្កើតឡើងដោយរដ្ឋលេខាធិការ លំដាប់ថ្នាក់ដែលបានបង្ហាញនៅលើសន្លឹកឆ្នោតនីមួយៗសម្រាប់ការបោះឆ្នោត ឬការបោះឆ្នោតបឋមនីមួយៗដែលត្រូវរាប់តាមផ្នែកនេះនឹងត្រូវបម្លែងទៅជាទម្រង់ដែលម៉ាស៊ីនអាចអានបាន ។ សន្លឹកឆ្នោតដែលត្រូវបានបម្លែងហើយ ត្រូវបញ្ចូលទៅក្នុងកុំព្យូទ័រដែលរដ្ឋលេខាធិការចាត់ទុកថាមានសមត្ថភាពអនុវត្តដំណើរការរាប់សន្លឹកឆ្នោតដែលបានពណ៌នាក្នុងផ្នែកទី 2B នៃជំពូកទី 50 ។ នៅពេលបញ្ចប់ជុំទាំងអស់នៃការរាប់សន្លឹកឆ្នោត រដ្ឋលេខាធិការ ឬមន្ត្រីបោះឆ្នោតដែលត្រូវបានចាត់តាំងដោយរដ្ឋលេខាធិការ ត្រូវប្រកាសជាសាធារណៈយ៉ាងច្បាស់លាស់ អាចស្តាប់បានដោយមានវត្តមាននៃមន្ត្រីបោះឆ្នោតផ្សេងទៀតអំពីចំនួននៃសំឡេងអាទិភាពសកម្មសម្រាប់បេក្ខជនបន្តនីមួយៗ នៅក្នុងជុំនីមួយៗសម្រាប់ការិយាល័យនីមួយៗដែលត្រូវបានរាប់នៅកន្លែងរាប់សន្លឹកឆ្នោតកណ្តាល ។ រដ្ឋលេខាធិការត្រូវពិនិត្យបន្ថែមលើរាល់ច្បាប់ដើម និងច្បាប់ចម្លងបន្ថែមទាំងអស់នៃកំណត់ត្រា និងបញ្ចូលពួកវាជាផ្នែកនៃកំណត់ត្រានៃការបោះឆ្នោត ឬការបោះឆ្នោតបឋមនោះ ហើយត្រូវបញ្ជាក់ និងបង្ហាញជាភស្តុតាងនូវច្បាប់ចម្លងកំណត់ត្រានៃសន្លឹកឆ្នោតសម្រាប់បណ្តាបេក្ខជននៅក្នុងជុំនីមួយៗនៃការរាប់សន្លឹកឆ្នោត ។

ផ្នែកទី 11. ផ្នែកទី 135 នៃជំពូកទី 54 ដែលបានលើកឡើង ត្រូវបានធ្វើវិសោធនកម្មដោយបន្ថែមកថាខណ្ឌខាងក្រោមបន្ទាប់ពីកថាខណ្ឌទីប្រាំពីរនៃផ្នែកដែលបានលើកឡើង៖—

ក្នុងករណីរាប់ឡើងវិញទូទាំងរដ្ឋ ឬទូទាំងមណ្ឌល ដូចដែលបានពណ៌នានៅកថាខណ្ឌពីរមុននេះ នៅក្នុងការបោះឆ្នោត ឬការបោះឆ្នោតបឋមក្រោមការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់ ហើយនៅពេលដែលសន្លឹកឆ្នោតនឹងត្រូវរាប់ ឬត្រូវបានគេរាប់នៅក្នុងកន្លែងរាប់សន្លឹកឆ្នោតកណ្តាលយោងតាមផ្នែកទី 105B នោះពេលវេលានៃការដាក់ញត្តិសម្រាប់ការរាប់ឡើងវិញនឹងត្រូវពន្យារដល់ ឬមុនម៉ោងប្រាំល្ងាច នៅថ្ងៃទីបីបន្ទាប់ពីការប្រកាសលទ្ធផលនៃការរាប់សន្លឹកឆ្នោតដែលត្រូវបានអនុវត្តដោយអនុលោមតាមផ្នែកទី 105B បើសិនជាពេលវេលាសម្រាប់ការដាក់ត្រូវបានផ្តល់ជូនក្នុងផ្នែកនេះបានផុតកាលបរិច្ឆេទដែលបានពន្យារនោះ ។

ផ្នែកទី 12. រដ្ឋលេខាធិការត្រូវប្រកាសឱ្យប្រើត្រឹមថ្ងៃទី 1 ខែតុលាឆ្នាំ 2021 នូវបទប្បញ្ញត្តិដែលត្រូវគ្នានឹងច្បាប់នេះ ហើយដែលធានាថាសន្លឹកឆ្នោតតាមរយៈការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់ត្រូវមានលក្ខណៈសាមញ្ញ និងងាយយល់ ។ លើសពីនេះ រដ្ឋលេខាធិការត្រូវធ្វើយុទ្ធនាការអប់រំអ្នកបោះឆ្នោតដើម្បីឲ្យអ្នកបោះឆ្នោតស្គាល់ពីការបោះឆ្នោតជ្រើសរើសតាមលំដាប់ថ្នាក់ ។

ផ្នែកទី 13. ច្បាប់នេះអនុវត្តចំពោះការបោះឆ្នោត និងការបោះឆ្នោតបឋមដែលធ្វើឡើងនៅថ្ងៃទី ឬក្រោយថ្ងៃទី 1 ខែមករា ឆ្នាំ 2022 ។

# ការបោះឆ្នោតនៅឆ្នាំ 2020

## ការបោះឆ្នោតនៅឆ្នាំ 2020



ការបោះឆ្នោតនៅឆ្នាំនេះទំនងជាមើលទៅខុសគ្នាបន្តិចបន្តួចជាងការបោះឆ្នោតកន្លងមក ។ ដើម្បីធានាថា អ្នករាល់គ្នាអាចបោះឆ្នោតដោយសុវត្ថិភាពនាឆ្នាំនេះ មានការផ្លាស់ប្តូរជាច្រើនបានធ្វើឡើងចំពោះច្បាប់ និងនីតិវិធីនៃការបោះឆ្នោតរបស់យើង ។

នៅឆ្នាំនេះនឹងមានវិធីជាច្រើនដើម្បីបោះឆ្នោតនៅរដ្ឋ Massachusetts ជាងពេលមុនៗ ។ អ្នកបោះឆ្នោតគ្រប់រូបអាចជ្រើសរើសបោះឆ្នោត ៖

- តាមសំបុត្រ ឬ
- ដោយបង្ហាញវត្តមានផ្ទាល់ នៅទីតាំងបោះឆ្នោតមុនកាលកំណត់ ឬ
- នៅថ្ងៃបោះឆ្នោត នៅការិយាល័យបោះឆ្នោតរបស់អ្នក ។

ការបោះឆ្នោតតាមសំបុត្រមានផ្តល់ជូននៅឆ្នាំនេះសម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់ ។ មិនចាំបាច់ដោះសារសម្រាប់ការបោះឆ្នោតតាមសំបុត្រទេ ។

ការបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នឹងនៅតែមាននៅគ្រប់សហគមន៍ទាំងអស់នៅថ្ងៃបោះឆ្នោត ក៏ដូចជាអំឡុងពេលបោះឆ្នោតមុនកាលកំណត់ ។ សូមមើលទំព័រទី 14 និងទី 15 សម្រាប់ព័ត៌មានអំពីការបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់ ។

# ការចុះឈ្មោះអ្នកបោះឆ្នោត

## ការចុះឈ្មោះអ្នកបោះឆ្នោត



មិនថាអ្នកមានគម្រោងបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់ ឬតាមសំបុត្រនោះទេ អ្នកត្រូវប្រាកដថា អ្នកបានចុះឈ្មោះបោះឆ្នោត ។ អ្នកអាចពិនិត្យមើលការចុះឈ្មោះអ្នកបោះឆ្នោតតាមអ៊ីនធឺណិតលើគេហទំព័រ **www.RegistertoVoteMA.com ។** ដើម្បីធានាថា មនុស្សគ្រប់រូបមានពេលវេលាគ្រប់គ្រាន់ដើម្បីចុះឈ្មោះបោះឆ្នោតនៅឆ្នាំនេះ កាលកំណត់នៃការចុះឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតឆ្នាំ 2020 ត្រូវបានកាត់បន្ថយមកត្រឹម 10 ថ្ងៃមុនពេលបោះឆ្នោត ។

ដើម្បីបោះឆ្នោតក្នុងការបោះឆ្នោតរដ្ឋថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020 អ្នកត្រូវចុះឈ្មោះបោះឆ្នោតត្រឹមថ្ងៃទី **24 ខែតុលា ឆ្នាំ 2020** ។

ថ្ងៃទី 24 ខែតុលាក៏ជាកាលកំណត់ដើម្បីធ្វើការផ្លាស់ប្តូរណាមួយលើការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក ដូចជាការផ្លាស់ប្តូរអាសយដ្ឋានផងដែរ ។

## របៀបចុះឈ្មោះបោះឆ្នោត

**តាមអ៊ីនធឺណិត** – បើអ្នកមានប័ណ្ណបើកបររបស់រដ្ឋ Massachusetts ឬអត្តសញ្ញាណប័ណ្ណរដ្ឋ អ្នកអាចចុះឈ្មោះបោះឆ្នោតតាមអ៊ីនធឺណិតលើគេហទំព័រ **www.RegisterToVoteMA.com** ។ អ្នកក៏អាចប្រើប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោតតាមអ៊ីនធឺណិតនេះ ដើម្បីធ្វើបច្ចុប្បន្នភាពអាសយដ្ឋាន ឬផ្លាស់ប្តូរសាខាគណបក្សនយោបាយរបស់អ្នកបានផងដែរ ។ ការចុះឈ្មោះតាមអ៊ីនធឺណិតត្រូវតែដាក់ជូនមិនលើសពីម៉ោង 11:59 យប់នៅថ្ងៃទី 24 ខែតុលាឡើយ ។

**តាមសំបុត្រ** – ប្រសិនបើអ្នកមិនអាចចុះឈ្មោះតាមអ៊ីនធឺណិតទេ អ្នកតែងតែមានជម្រើសក្នុងការចុះឈ្មោះបោះឆ្នោតតាមសំបុត្រ ។ ទម្រង់ចុះឈ្មោះបោះឆ្នោតតាមសំបុត្រត្រូវបានភ្ជាប់មកជាមួយកូនសៀវភៅនេះ ។ ទម្រង់ចុះឈ្មោះបោះឆ្នោតតាមសំបុត្រអាចបោះពុម្ពបាននៅលើគេហទំព័រ **www.sec.state.ma.us/ele** ឬស្នើសុំដោយទូរស័ព្ទទៅកាន់លេខ 1-800-462-VOTE (8683) ។ រាល់ការចុះឈ្មោះបោះឆ្នោតតាមសំបុត្រត្រូវតែបង់ថ្លៃប្រៃសណីយ៍ ឬប្រគល់ទៅសាលាក្រុង ឬទីក្រុងរបស់អ្នកត្រឹមថ្ងៃទី 24 ខែតុលា ។

**ដោយបង្ហាញវត្តមានផ្ទាល់** – ការចុះឈ្មោះបោះឆ្នោតអាចរកបាននៅការិយាល័យបោះឆ្នោតក្នុងតំបន់នីមួយៗដែលជាទូទៅមានទីតាំងនៅទីក្រុង ឬសាលាក្រុងរបស់អ្នក ។ អ្នកអាចរកការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នកនៅលើគេហទំព័រ **www.sec.state.ma.us/ele** ។ ការិយាល័យបោះឆ្នោតក្នុងតំបន់ទាំងអស់ត្រូវផ្តល់ជូនការចុះឈ្មោះបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅថ្ងៃទី 24 ខែតុលាចាប់ពីម៉ោង 2 រសៀល– 4 រសៀល និងពីម៉ោង 7 យប់– 8 យប់ ។

# ការបោះឆ្នោតតាមសំបុត្រ



នៅឆ្នាំនេះ រាល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះក្នុងរដ្ឋ Massachusetts អាចបោះឆ្នោតតាមសំបុត្រដោយមិនអាចដោះសារមិនធ្វើដូច្នេះបានឡើយ ។ ដើម្បីបោះឆ្នោតតាមសំបុត្រ អ្នកត្រូវដាក់សំណើជាលាយលក្ខណ៍អក្សរទៅមន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋានរបស់អ្នក ។ អ្នកប្រហែលជាបានទទួលទម្រង់ដាក់ពាក្យសុំតាមសំបុត្រដែលត្រូវបានផ្ញើទៅអ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់ ដែលមិនទាន់បានដាក់ពាក្យសុំបោះឆ្នោតតាមសំបុត្រ ។

ប្រសិនបើអ្នកបានដាក់ពាក្យសុំបោះឆ្នោតតាមសំបុត្ររួចហើយ សន្លឹកឆ្នោតរបស់អ្នកគួរតែត្រូវបានផ្ញើទៅអ្នកឆាប់ៗនេះ ។ អ្នកអាចតាមដានសន្លឹកឆ្នោតរបស់អ្នកតាមអ៊ីនធឺណិតលើគេហទំព័រ **www.TrackMyBallotMA.com**

បើអ្នកចង់បោះឆ្នោតតាមសំបុត្រ ហើយមិនទាន់បានដាក់ពាក្យសុំនោះទេ សូមអនុវត្តតាមជំហានខាងក្រោម ដើម្បីស្នើសុំសន្លឹកឆ្នោតរបស់អ្នក ។

## វិធីបោះឆ្នោតតាមសំបុត្រ

1. **សូមពិនិត្យមើលការចុះឈ្មោះបោះឆ្នោតរបស់អ្នកលើគេហទំព័រ www.RegisterToVoteMA.com ។**

   បើអ្នកមិនបានចុះឈ្មោះនៅអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកទេ អ្នកត្រូវតែធ្វើបច្ចុប្បន្នភាពការចុះឈ្មោះរបស់អ្នកមុនពេលដាក់ពាក្យស្នើសុំការបោះឆ្នោតតាមសំបុត្ររបស់អ្នក ។ កាលកំណត់ដើម្បីធ្វើការផ្លាស់ប្តូរណាមួយលើការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកគឺនៅថ្ងៃទី **24 ខែតុលា** ។

2. **ដាក់ពាក្យសុំបោះឆ្នោតតាមសំបុត្រលើគេហទំព័រ www.MailMyBallotMA.com ។**

   អ្នកអាចបំពេញទម្រង់ដាក់ពាក្យសុំដោយដៃ ឬតាមប្រព័ន្ធអេឡិចត្រូនិចបាន ។ ត្រូវប្រាកដថាបញ្ចូលអាសយដ្ឋានដែលអ្នកចង់ឲ្យគេផ្ញើសន្លឹកឆ្នោតជូនអ្នក ប្រសិនបើអាសយដ្ឋាននោះខុសពីអាសយដ្ឋានដែលអ្នកបានចុះឈ្មោះបោះឆ្នោត ។

   បើអ្នកចង់បានទម្រង់ដាក់ពាក្យសុំជាទម្រង់ក្រដាសដែលផ្ញើមកអ្នក សូមទូរស័ព្ទមកនាយកដ្ឋានបោះឆ្នោតតាមលេខ 1-800-462-VOTE (8683) ដើម្បីស្នើសុំទម្រង់ជាក្រដាសមួយ ។ ជាជម្រើសផ្សេង អ្នកអាចដាក់ពាក្យសុំដោយគ្រាន់តែសរសេរសំបុត្រទៅមន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋានរបស់អ្នកប៉ុណ្ណោះ ។ លិខិតនោះត្រូវរួមបញ្ចូលឈ្មោះរបស់អ្នក អាសយដ្ឋានដែលអ្នកបានចុះឈ្មោះបោះឆ្នោត អាសយដ្ឋានដែលអ្នកចង់ឲ្យគេផ្ញើសន្លឹកឆ្នោតតាមសំបុត្រ និងហត្ថលេខារបស់អ្នក ។

3. **ដាក់ទម្រង់ពាក្យសុំរបស់អ្នក** ទៅការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នកឱ្យបានឆាប់បំផុត ។

   ទម្រង់ដាក់ពាក្យសុំបោះឆ្នោតតាមសំបុត្ររបស់អ្នកត្រូវតែទៅដល់ការិយាល័យបោះឆ្នោតក្នុងតំបន់របស់អ្នកមិនឲ្យលើសពីថ្ងៃទី **28 ខែតុលា**ឡើយ ។ គួរតែដាក់ទម្រង់ពាក្យសុំបោះឆ្នោតតាមសំបុត្រយ៉ាងតិច 2 សប្តាហ៍មុនថ្ងៃបោះឆ្នោត ។

   ទម្រង់ដាក់ពាក្យសុំអាចដាក់តាមអ៊ីនធឺណិត តាមសំបុត្រ តាមអ៊ីមែល តាមទូរសារ ឬដោយបង្ហាញវត្តមានផ្ទាល់ ។ អ្នកអាចស្វែងរកព័ត៌មានទំនាក់ទំនងសម្រាប់ការិយាល័យបោះឆ្នោតមូលដ្ឋានរបស់អ្នកលើគេហទំព័រ **www.sec.state.ma.us/ele ។**

4. **សូមរង់ចាំសន្លឹកឆ្នោតរបស់អ្នកផ្ញើមកដល់សិន ។**

   មន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋាននឹងចាប់ផ្តើមផ្ញើសន្លឹកឆ្នោតនៅដើមខែតុលា ហើយនឹងបន្តផ្ញើសន្លឹកឆ្នោតនៅពេលទម្រង់ដាក់ពាក្យសុំផ្ញើមកដល់រហូតដល់កាលកំណត់នៃការទទួលពាក្យត្រឹមថ្ងៃទី 28 ខែតុលា ។

5. **ផ្ញើសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញ ។**

   សន្លឹកឆ្នោតទាំងអស់ដែលផ្ញើមកវិញតាមសំបុត្រត្រូវតែ **បង់ថ្លៃប្រៃសណីយ៍ត្រឹមថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020** ហើយត្រូវតែ **ទៅដល់ដៃមន្ត្រីរៀបចំការបោះឆ្នោតរបស់អ្នកនៅថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2020 ដើម្បីឲ្យគេរាប់សន្លឹកឆ្នោត ។**

   កញ្ចប់សន្លឹកឆ្នោតបោះតាមសំបុត្រនៅឆ្នាំ 2020 នឹងរួមបញ្ចូលនូវស្រោមសំបុត្រដែលបានបង់ប្រាក់មុនផ្ញើតាមប្រៃសណីយ៍ និងចុះអាសយដ្ឋានជាមុនសម្រាប់ឲ្យអ្នកប្រើដើម្បីផ្ញើត្រឡប់ទៅការិយាល័យបោះឆ្នោតមូលដ្ឋានរបស់អ្នកវិញ ។ អ្នកក៏អាចប្រគល់សន្លឹកឆ្នោតរបស់អ្នកមកវិញដោយបង្ហាញវត្តមានផ្ទាល់ទៅការិយាល័យបោះឆ្នោតមូលដ្ឋានផងដែរ ។

បើអ្នកសម្រេចចិត្តមិនទៅបោះឆ្នោតតាមសំបុត្រ អ្នកអាចបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់ក្នុងអំឡុងពេលបោះឆ្នោតមុនកាលកំណត់ ឬនៅថ្ងៃបោះឆ្នោតដរាបណាសន្លឹកឆ្នោតរបស់អ្នកមិនត្រូវបានទទួលយកនៅការិយាល័យបោះឆ្នោតមូលដ្ឋានរបស់អ្នក ។ **នៅពេលសន្លឹកឆ្នោតរបស់អ្នកត្រូវបានទទួលយក អ្នកមិនអាចដកមកវិញ ឬបោះឆ្នោតម្តងទៀតបានទេ ។**



សេវាប្រៃសណីយ៍សហរដ្ឋអាមេរិកណែនាំឱ្យផ្ញើសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញយ៉ាងហោចណាស់ **7 ថ្ងៃមុនថ្ងៃបោះឆ្នោត ។**

# ការបោះឆ្នោតមុនកាលកំណត់ ៖ ថ្ងៃទី 17 – 30 ខែតុលា



ឆ្នាំនេះអ្នកបោះឆ្នោតនឹងមានឱកាសបោះឆ្នោតច្រើនជាងពេលណាៗទាំងអស់ ។ ការបោះឆ្នោតមុនកាលកំណត់ដោយបង្ហាញវត្តមានផ្ទាល់អាចត្រូវបានពន្យារពេល និងរាប់បញ្ចូលទាំងបួនថ្ងៃចុងសប្តាហ៍ ដូច្នេះអ្នកបោះឆ្នោតដែលចង់បោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់អាចបោះឆ្នោតដោយងាយស្រួល ។

ដោយមានចំនួនថ្ងៃបន្ថែមនៃការបោះឆ្នោតមុនកាលកំណត់ ការបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នឹងធ្វើឡើងក្នុងរយៈពេល 15 ថ្ងៃក្នុងគោលបំណងកាត់បន្ថយចំនួនមនុស្សនៅក្នុងការិយាល័យបោះឆ្នោត និងទីតាំងបោះឆ្នោតមុនកាលកំណត់ ។

## អ្នកណា?

រាល់អ្នកបោះឆ្នោតដែលបានចុះឈ្មោះរួច ហើយដែលមិនទាន់បានទៅបោះឆ្នោតតាមសំបុត្រអាចបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់មុនកាលកំណត់ ។ មិនត្រូវការលេះសារសម្រាប់ការបោះឆ្នោតមុនកាលកំណត់ឡើយ ។

## ពេលណា?

រយៈពេលបោះឆ្នោតមុនកាលកំណត់នឹងចាប់ផ្តើមនៅថ្ងៃសៅរ៍ទី 17 ខែតុលា និងបញ្ចប់នៅថ្ងៃសុក្រទី 30 ខែតុលា ។ នៅរៀងរាល់ថ្ងៃធ្វើការ ទីក្រុង និងក្រុងនីមួយៗត្រូវផ្តល់ការបោះឆ្នោតមុនកាលកំណត់យ៉ាងហោចណាស់នៅទីតាំងមួយក្នុងអំឡុងម៉ោងធ្វើការធម្មតារបស់ការិយាល័យបោះឆ្នោតមូលដ្ឋាន ។ នៅរៀងរាល់ថ្ងៃចុងសប្តាហ៍នៃថ្ងៃទី 17-18 ខែតុលា និងថ្ងៃទី 24-25 ខែតុលា សហគមន៍នីមួយៗត្រូវតែបើកជារៀងរាល់ថ្ងៃ ។ ចំនួនម៉ោងដែលសហគមន៍នីមួយៗត្រូវបើកនៅចុងសប្តាហ៍អាស្រ័យលើទំហំនៃទីក្រុង ឬក្រុង ។

សម្គាល់ ៖ ទីក្រុង និងក្រុងជាច្រើនមានម៉ោងធ្វើការមានកំណត់នៅរាល់ថ្ងៃសុក្រ ។ ត្រូវប្រាកដថាពិនិត្យមើលកាលវិភាគបោះឆ្នោតមុនកាលកំណត់របស់សហគមន៍អ្នកនៅលើគេហទំព័រ **www.MassEarlyVote.com** នៅពេលដែលធ្វើផែនការបោះឆ្នោត ។

## កន្លែងណា ?

អ្នកអាចបោះឆ្នោតមុនកាលកំណត់នៅទីតាំងបោះឆ្នោតមុនកាលកំណត់ណាមួយនៅក្នុងទីក្រុង ឬក្រុងដែលអ្នកបានចុះឈ្មោះបោះឆ្នោត ។ ទីក្រុង និងក្រុងទាំងអស់ត្រូវមានទីតាំងបោះឆ្នោតមុនកាលកំណត់យ៉ាងហោចណាស់មួយកន្លែង ប៉ុន្តែពួកគេអាចជ្រើសរើសមានច្រើនទីតាំងបាន ។ ទីតាំងបោះឆ្នោតមុនកាលកំណត់ត្រូវបានជ្រើសរើសដោយទីក្រុង និងក្រុងនីមួយៗ ហើយនឹងត្រូវបោះពុម្ពផ្សាយនៅលើគេហទំព័រ **www.MassEarlyVote.com** យ៉ាងហោចណាស់ 1 សប្តាហ៍មុនពេលការបោះឆ្នោតចាប់ផ្តើម ។

## ដោយរបៀបណា?

អ្នកមិនចាំបាច់ធ្វើការណាត់ជួប ឬដាក់ពាក្យសុំបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់មុនកាលកំណត់នោះទេ ។ អ្នកប្រហែលគ្រាន់តែទៅកាន់ទីតាំងបោះឆ្នោតមុនកាលកំណត់ណាមួយនៅក្នុងទីក្រុង ឬក្រុងរបស់អ្នក ហើយបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់ដូចជាអ្នកធ្វើនៅថ្ងៃបោះឆ្នោតអញ្ចឹង ។ បន្ទាប់ពីអ្នកបានបោះឆ្នោតចប់រួចរាល់ហើយ អ្នកនឹងបោះត្រាលើសន្លឹកឆ្នោតរបស់អ្នកនៅក្នុងស្រោមសំបុត្រសន្លឹកឆ្នោត ហើយចុះហត្ថលេខាលើលិខិតថ្លែងសច្ចាលើស្រោមសំបុត្រ ហើយប្រគល់ទៅឲ្យមន្ត្រីរៀបចំការបោះឆ្នោតវិញ ។ នៅពេលអ្នកប្រគល់ស្រោមសំបុត្រសន្លឹកឆ្នោតរបស់អ្នក ហើយស្មៀនទទួលយកសំបុត្រនោះការបោះឆ្នោតរបស់អ្នកចប់ស្ថាពរ ហើយអ្នកមិនអាចដកវាមកវិញ ឬបោះឆ្នោតម្តងទៀតបានទេ ។

## ចងចាំ៖

ដូចការិយាល័យបោះឆ្នោតជាច្រើននៅថ្ងៃបោះឆ្នោតអញ្ចឹងដែរ ទីតាំងបោះឆ្នោតមុនកាលកំណត់នឹងត្រូវបានបង្កើតឡើង ដើម្បីអនុញ្ញាតឱ្យមានការរក្សាគម្លាតសុវត្ថិភាពក្នុងសង្គម ។ ចំនួនអ្នកបោះឆ្នោតដែលអនុញ្ញាតនៅក្នុងទីតាំងបោះឆ្នោតមុនកាលកំណត់ទាន់ពេលវេលាអាចមានកំណត់ ហើយអ្នកបោះឆ្នោតដែលឈរតម្រង់ជួរ ដើម្បីចូលទៅកាន់ទីតាំងបោះឆ្នោតមុនកាលកំណត់នឹងត្រូវគេរៀបចំកំណត់ចន្លោះយ៉ាងត្រឹមត្រូវ ដែលអាចធ្វើឱ្យខ្សែបន្ទាត់តម្រង់ជួរវែងខុសជាងធម្មតា ។

ខ្សែបន្ទាត់តម្រង់ជួរនៅទីតាំងបោះឆ្នោតមុនកាលកំណត់ គឺមានប្រវែងវែងនៅថ្ងៃដំបូង និងថ្ងៃចុងក្រោយនៃរយៈពេលបោះឆ្នោតមុនកាលកំណត់ ។ ខ្សែបន្ទាត់តម្រង់ជួរក៏អាចវែងជាងនៅរាល់ចុងសប្តាហ៍ផងដែរ ។ អ្នកបោះឆ្នោតដែលអាចបោះឆ្នោតបានក្នុងម៉ោងមិនសូវមមាញឹកត្រូវបានលើកទឹកចិត្តឱ្យធ្វើដូច្នេះ ។

ក្នុងករណីភាគច្រើន មានការិយាល័យបោះឆ្នោតជាច្រើននៅតាមទីក្រុង និងក្រុងនីមួយៗនៅថ្ងៃបោះឆ្នោតច្រើនជាងមានកន្លែងបោះឆ្នោតមុនកាលកំណត់ ដែលមានន័យថាមានចំនួនប្រជាជនតិចទៅបោះឆ្នោតនៅពេលវេលាកំណត់នៅការិយាល័យបោះឆ្នោតរបស់អ្នកគឺតិចជាងនៅទីតាំងបោះឆ្នោតមុនកាលកំណត់របស់អ្នក ។ មិនថាអ្នកបោះឆ្នោតនៅទីណា ឬបោះឆ្នោតពេលណានោះទេ ការិយាល័យបោះឆ្នោតនឹងត្រូវរៀបចំឡើងដើម្បីឲ្យអ្នករាល់គ្នាអាចបោះឆ្នោតបានដោយសុវត្ថិភាព ។

**អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់ដែលមិនបានបោះឆ្នោតតាមសំបុត្រ ឬបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់មុនកាលកំណត់នឹងអាចបោះឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ពួកគេនៅថ្ងៃអង្គារទី 3 ខែវិច្ឆិកា ឆ្នាំ 2020 ចាប់ពីម៉ោង 7 ព្រឹករហូតដល់ម៉ោង 8 យប់ ។**

# *ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត*

**អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់ដែលមិនបានបោះឆ្នោតតាមសំបុត្រ ឬបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់មុនកាលកំណត់នឹងអាចបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅថ្ងៃបោះឆ្នោតនៅទី 3 ខែវិច្ឆិកា ឆ្នាំ 2020 ។ ការិយាល័យបោះឆ្នោតនៅទូទាំងរដ្ឋ Massachusetts នឹងបើកពីម៉ោង 7 ព្រឹករហូតដល់ម៉ោង 8 យប់ ។**

## វិធានការការពារសុវត្ថិភាព

ប្រសិនបើអ្នកកំពុងបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅថ្ងៃទី 3 ខែវិច្ឆិកា ឆ្នាំ 2020 ឬក្នុងអំឡុងពេលបោះឆ្នោតមុនកាលកំណត់ ដំណើរការបោះឆ្នោតនៅឆ្នាំនេះអាចមើលទៅ និងមានអារម្មណ៍ខុសប្លែកពីការបោះឆ្នោតកន្លងមក ។ ទីតាំងបោះឆ្នោតទាំងអស់នឹងរៀបចំឡើង ដើម្បីអនុញ្ញាតឱ្យរក្សាគម្លាតសុវត្ថិភាពនៅក្នុងសង្គម ។ ចំនួនអ្នកបោះឆ្នោតដែលអនុញ្ញាតនៅខាងក្នុងការិយាល័យបោះឆ្នោតនៅពេលណាមួយអាចត្រូវបានដាក់កំណត់ ដើម្បីចៀសវាងការប្រមូលផ្តុំកកកុញ ។ នេះមានន័យថាអ្នកប្រហែលជាត្រូវរង់ចាំតម្រង់ជួរខាងក្រៅការិយាល័យបោះឆ្នោតរបស់អ្នកមុនពេលចូលបោះឆ្នោត ។ អ្នកបោះឆ្នោតដែលតម្រង់ជួរគួរតែនៅឆ្ងាយពីគ្នានៅពេលពួកគេកំពុងរង់ចាំ ដែលអាចធ្វើឱ្យខ្សែបន្ទាត់តម្រង់ជួរមើលទៅហាក់ដូចជាវែងជាងធម្មតា ។ សូមអត់ធ្មត់ចំពោះមន្ត្រីរៀបចំការបោះឆ្នោតនៅពេលដែលពួកគេធ្វើការ ដើម្បីធានាថាអ្នកអាចបោះឆ្នោតបានយ៉ាងឆាប់រហ័ស និងដោយសុវត្ថិភាព ។

អនុលោមតាមការណែនាំរបស់ក្រសួងសុខាភិបាលសាធារណៈ (DPH) និងមជ្ឈមណ្ឌលគ្រប់គ្រងជំងឺ (CDC) អ្នកបោះឆ្នោតទាំងអស់ត្រូវបានណែនាំឲ្យពាក់ម៉ាស់ ឬម៉ាស់ក្រណាត់នៅការិយាល័យបោះឆ្នោត និងពេលឈរតម្រង់ជួរ ប្រសិនបើពួកគេអាចធ្វើដូច្នេះបាន ។ អ្នកបោះឆ្នោតដែលមិនអាចពាក់ម៉ាស់នឹងនៅតែត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតដោយមានការសម្របសម្រួលសមស្រប ដើម្បីធានាថា ពួកគេនៅតែឃ្លាតឆ្ងាយពីអ្នកបោះឆ្នោត និងមន្ត្រីរៀបចំការបោះឆ្នោតដទៃទៀតដោយសុវត្ថិភាព ។

មន្ត្រីរៀបចំការបោះឆ្នោតត្រូវបានណែនាំឱ្យធ្វើអនាម័យរាល់ផ្ទៃដែលប៉ះរួមរាល់ពេលប្រើប្រាស់ម្តងៗ ។ ខណៈពេលដែលគេផ្តល់ប៊ិចឲ្យអ្នកគូសសន្លឹកឆ្នោតរបស់អ្នក ដែលប៊ិចនេះនឹងត្រូវបានសម្អាតធ្វើអនាម័យជាញឹកញាប់ អ្នកអាចយកប៊ិចខ្មៅផ្ទាល់ខ្លួនរបស់អ្នកទៅជាមួយដើម្បីគូសសន្លឹកឆ្នោតរបស់អ្នកបាន ។

## ដំណើរការបោះឆ្នោត

នៅពេលអ្នកទៅដល់ការិយាល័យបោះឆ្នោត អ្នកនឹងត្រូវបានគេស្នើសុំឲ្យចុះឈ្មោះចូល ។ អ្នកត្រូវផ្តល់អាសយដ្ឋាន និងឈ្មោះរបស់អ្នកដល់មន្ត្រីរៀបចំការបោះឆ្នោតដែលនឹងរកមើលឈ្មោះរបស់អ្នកនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ។ មន្ត្រីរៀបចំការបោះឆ្នោតត្រូវបញ្ជាក់អាសយដ្ឋាន និងឈ្មោះរបស់អ្នកឡើងវិញមុនពេលគូសសញ្ញាសម្គាល់នៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ។ អ្នកបោះឆ្នោតដែលបានបោះឆ្នោតរួចហើយតាមសំបុត្រ ឬក្នុងអំឡុងពេលបោះឆ្នោតមុនកាលកំណត់នឹងត្រូវបានគេគូសសម្គាល់ថាបោះឆ្នោតរួចហើយនៅក្នុងបញ្ជី ។

នៅពេលដែលអ្នកបានចុះឈ្មោះចូលរួចហើយ គេនឹងផ្តល់សន្លឹកឆ្នោតមួយសន្លឹកឲ្យអ្នកដើម្បីបោះឆ្នោត និងនាំអ្នកទៅតូបបោះឆ្នោត ។ ត្រូវប្រាកដថា អ្នកបានអានសន្លឹកឆ្នោតទាំងសងខាងដែលអាចមាននៅលើសន្លឹកប័ណ្ណពីរផ្សេងគ្នា ។ ប្រសិនបើអ្នកគូសសន្លឹកឆ្នោតរបស់អ្នកខុស អ្នកអាចស្នើសុំសន្លឹកឆ្នោតថ្មីបាន ។ ពេលអ្នកគូសសន្លឹកឆ្នោតរបស់អ្នករួចរាល់ហើយ បន្ទាប់មក អ្នកអាចបោះឆ្នោតបាន រួចហើយអ្នកអាចចេញពីការិយាល័យបោះឆ្នោតបាន ។

## ជំនួយនៅពេលបោះឆ្នោត

ប្រសិនបើអ្នកត្រូវការជំនួយដោយសារមានបញ្ហាភ្នែក ពិការភាព ឬអសមត្ថភាពក្នុងការអាន ឬអានភាសាអង់គ្លេសនោះ អ្នកអាចស្វែងរកជំនួយពីបុគ្គលណាម្នាក់តាមជម្រើសរបស់អ្នកបាន ដែលរួមមានមន្ត្រីរៀបចំការបោះឆ្នោតនៅការិយាល័យបោះឆ្នោតរបស់អ្នក ។ អ្នកក៏អាចស្នើសុំឱ្យមន្ត្រីរៀបចំការបោះឆ្នោតប្រើឧបករណ៍ជំនួយគូសសន្លឹកឆ្នោត AutoMARK ដែលជាឧបករណ៍គូសសន្លឹកឆ្នោតដែលអាចចូលបាន និងអនុញ្ញាតឱ្យអ្នកគូសសន្លឹកឆ្នោតរបស់អ្នកដោយឯកជន និងដោយឯករាជ្យបាន ។ បន្ទាប់ពីស៊កសន្លឹកឆ្នោតចូលទៅក្នុងឧបករណ៍ AutoMARK រួចហើយ អ្នកអាចពិនិត្យសន្លឹកឆ្នោតឡើងវិញ និងធ្វើការជ្រើសរើសដោយប្រើការចុចលើផ្ទៃអេក្រង់ និង/ឬក្តារចុចខណៈពេលដែលស្តាប់សន្លឹកឆ្នោតតាមកាសទូរស័ព្ទ ។ ឧបករណ៍ AutoMARK នឹងគូសសន្លឹកឆ្នោតស្របតាមជម្រើសរបស់អ្នក ដោយបំពេញនៅក្នុងប្រអប់រាងពងក្រពើដែលត្រូវគ្នា ឬមានភ្ជាប់សញ្ញាព្រួញនៅលើសន្លឹកឆ្នោត ។ សន្លឹកឆ្នោតនឹងត្រូវប្រគល់ជូនអ្នកវិញដើម្បីដាក់ចូលក្នុងប្រអប់ឆ្នោត ។

## អ្នកបោះឆ្នោតដែលចូលដេកនៅមន្ទីរពេទ្យមុនថ្ងៃបោះឆ្នោត

អ្នកបោះឆ្នោតណាដែលចូលដេកនៅមណ្ឌលសុខភាព ឬត្រូវបានណែនាំដោយមន្ត្រីសុខាភិបាលឱ្យធ្វើចត្តាឡីស័កដោយខ្លួនឯងបន្ទាប់ពីថ្ងៃទីប្រាំពីរមុនការបោះឆ្នោត (ថ្ងៃអង្គារទី 27 ខែតុលា ឆ្នាំ 2020) អាចស្នើសុំសន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមានរហូតដល់ម៉ោងបិទការបោះឆ្នោតបាន ។ អ្នកត្រូវតែបញ្ជាក់ជាលាយលក្ខណ៍អក្សរថា អ្នកបំពេញបានគ្រប់តាមលក្ខណៈសម្បត្តិនេះ ហើយត្រូវចាត់តាំងនរណាម្នាក់ (ដែលមិនមែនជាបេក្ខជនឈរឈ្មោះ) ដើម្បីយកសន្លឹកឆ្នោតឲ្យអ្នក ។ ក្រោយពេលបោះឆ្នោតរួច សន្លឹកឆ្នោតត្រូវប្រគល់ជូនមន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋានមុនពេលការិយាល័យបោះឆ្នោតបិទ ។

### *ការក្រើនរំលឹក!* សូមយកអត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួនទៅការិយាល័យបោះឆ្នោត !

លោកអ្នកអាចត្រូវបានគេទាមទារឱ្យបង្ហាញអត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួន ដើម្បីបោះឆ្នោត ។ បើវាជាការបោះឆ្នោតលើកដំបូងរបស់អ្នកនៅរដ្ឋ Massachusetts ឬបើអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតអសកម្ម អ្នកអាចត្រូវបានស្នើសុំឱ្យបង្ហាញអត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួន ។ គេបានផ្តល់អនុសាសន៍ថា អ្នកបោះឆ្នោតទាំងអស់ ត្រូវត្រៀមរៀបចំបង្ហាញ អត្តសញ្ញាណប័ណ្ណនៅថ្ងៃបោះឆ្នោត ។ មិនទាមទារអត្តសញ្ញាណប័ណ្ណមានរូបថតទេ ។ អត្តសញ្ញាណប័ណ្ណដែលអាចទទួលយកបាន ត្រូវតែមានឈ្មោះ និងអាសយដ្ឋានដែលអ្នកបានចុះឈ្មោះបោះឆ្នោត ឧទាហរណ៍ៈ ប័ណ្ណបើកបរយានយន្តថ្មី និងមានសុពលភាព អត្តសញ្ញាណប័ណ្ណមានរូបថត សំបុត្រទារថ្លៃយូធីលីធីថ្មី របាយការណ៍ធនាគារ កន្ទុយសន្លឹកប្រាក់ខែ សែករដ្ឋាភិបាល លិខិតពីអន្តេវាសិកដ្ឋាននៅលើក្បាលលិខិតសាលា ឬឯកសារផ្លូវការ និងថ្មីផ្សេងទៀត ដែលបង្ហាញឈ្មោះរបស់អ្នក និងអាសយដ្ឋានដែលអ្នកបានចុះបញ្ជីឈ្មោះ ។ អ្នកអាចបង្ហាញអត្តសញ្ញាណប័ណ្ណអេឡិចត្រូនិចដល់មន្ត្រីរៀបចំការបោះឆ្នោតដូចជានៅលើទូរស័ព្ទស្មាតហ្វូនបាន បើអ្នកមិនមានឯកសារជាទម្រង់ក្រដាស ។

## ការបោះឆ្នោតតាមសំបុត្រ

**តើខ្ញុំត្រូវបោះឆ្នោតតាមសំបុត្រឬទេ ?**

ទេ ។ ការបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់នៅតែមានផ្តល់ជូនសម្រាប់អ្នកដែលមិនចង់បោះឆ្នោតតាមសំបុត្រ ។

**តើខ្ញុំត្រូវដាក់ពាក្យសុំក្នុងរយៈពេលឆាប់ប៉ុនណា ?**

ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន! ពាក្យសុំរបស់អ្នកត្រូវតែទៅដល់ការិយាល័យបោះឆ្នោតមូលដ្ឋានរបស់អ្នកត្រឹមថ្ងៃទី **28 ខែតុលា**ប៉ុន្តែការផ្ញើតាមសំបុត្រអាចចំណាយពេល 1 សប្តាហ៍ ដូច្នេះអ្នកដាក់ពាក្យសុំកាន់តែឆាប់ អ្នកនឹងត្រូវផ្ញើសន្លឹកឆ្នោតមកវិញដោយចំណាយពេលវេលាកាន់តែច្រើន ហើយត្រូវប្រាកដថាសន្លឹកឆ្នោតនោះត្រូវបានគេរាប់ ។

**ប្រសិនបើខ្ញុំស្នើសុំសន្លឹកឆ្នោតបោះតាមសំបុត្រ តើខ្ញុំអាចផ្លាស់ប្តូរចិត្ត និងបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់បានទេ ?**

ប្រហែលជាអាចបាន ។ នៅពេលសន្លឹកឆ្នោតរបស់អ្នកត្រូវបានប្រគល់ឱ្យវិញ និងទទួលយកដោយមន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋានរបស់អ្នករួចហើយ អ្នកមិនអាចដកវាមកវិញ ឬបោះឆ្នោតម្តងទៀតបានទេ ។ បើអ្នកស្នើសុំសន្លឹកឆ្នោតបោះតាមសំបុត្រ ប៉ុន្តែអ្នកមិនផ្ញើវាទៅឲ្យមន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋានរបស់អ្នកទេ អ្នកអាចបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់ក្នុងអំឡុងពេលបោះឆ្នោតមុនកាលកំណត់ ឬនៅថ្ងៃបោះឆ្នោតបាន ។

**តើការបោះឆ្នោតតាមសំបុត្រមានសុវត្ថិភាពដែរឬទេ ?**

មាន ។ មុនពេលមន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋានរបស់អ្នកអាចផ្ញើសន្លឹកឆ្នោតឲ្យអ្នក អ្នកត្រូវបញ្ជាក់ថាអ្នកជាអ្នកបោះឆ្នោត ហើយកត់ត្រាពាក្យសុំរបស់អ្នក ។ នៅពេលមន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋានរបស់អ្នកទទួលបានសន្លឹកឆ្នោតរបស់អ្នក ពួកគេនឹងពិនិត្យដើម្បីប្រាកដថាអ្នកបានចុះហត្ថលេខាលើស្រោមសំបុត្រសន្លឹកឆ្នោត ហើយប្រៀបធៀបហត្ថលេខាជាមួយនឹងហត្ថលេខានៅលើឯកសារ ។ នេះជាការសំខាន់ ពីព្រោះសន្លឹកឆ្នោតត្រូវតែបដិសេធចោល ប្រសិនបើស្រោមសំបុត្រមិនមានចុះហត្ថលេខា ។ ប្រសិនបើសន្លឹកឆ្នោតរបស់អ្នកត្រូវបានទទួលយក គេនឹងគូសសម្គាល់អ្នកនៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោត ហើយសន្លឹកឆ្នោតរបស់អ្នកនឹងត្រូវបានរក្សាទុកដោយមន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋានរហូតដល់ពេលគេរាប់សន្លឹកឆ្នោត ។

**តើកាលកំណត់នៃការផ្ញើសន្លឹកឆ្នោតបោះតាមសំបុត្រគឺនៅថ្ងៃណា ?**

ដើម្បីឲ្យគេរាប់សន្លឹកឆ្នោតរបស់អ្នក សន្លឹកឆ្នោតត្រូវតែផ្ញើតាមប្រៃសណីយដោយបង់ថ្លៃសេវាប្រៃសណីយត្រឹមថ្ងៃទី **3 ខែវិច្ឆិកា ឆ្នាំ 2020** និងទទួលបានសន្លឹកឆ្នោតនេះមិនលើសពីថ្ងៃទី **6 ខែវិច្ឆិកា ឆ្នាំ 2020** ។ សេវាប្រៃសណីយ៍ណែនាំឱ្យអ្នកផ្ញើសន្លឹកឆ្នោតរបស់អ្នកត្រឡប់មកវិញយ៉ាងហោចណាស់មួយសប្តាហ៍មុនថ្ងៃបោះឆ្នោត ។

**តើខ្ញុំអាចពិនិត្យមើលថាគេទទួលសន្លឹកឆ្នោតរបស់ខ្ញុំហើយឬនៅដោយរបៀបណា?**

អ្នកអាចពិនិត្យមើលស្ថានភាពសន្លឹកឆ្នោតរបស់អ្នកតាមអ៊ីនធឺណិតនៅលើគេហទំព័រ **www.TrackMyBallotMA.com** ។ នៅពេលដែលគេបានទទួលពាក្យសុំរបស់អ្នក វាបង្ហាញកាលបរិច្ឆេទដែលមន្ត្រីរៀបចំការបោះឆ្នោតមូលដ្ឋានផ្ញើសន្លឹកឆ្នោតរបស់អ្នកទៅអ្នក និងកាលបរិច្ឆេទដែលសន្លឹកឆ្នោតរបស់អ្នកទៅដល់ការិយាល័យបោះឆ្នោតមូលដ្ឋាន ។

**តើសន្លឹកឆ្នោតបោះតាមសំបុត្រត្រូវបានរាប់ទាំងអស់ឬ?**

រាល់សន្លឹកឆ្នោតដែលបានទទួលទាន់ពេលនឹងត្រូវបានរាប់ បើសិនជាពួកវាត្រូវបានប្រតិបត្តិត្រឹមត្រូវ ។ កុំភ្លេចចុះហត្ថលេខាលើស្រោមសំបុត្រសន្លឹកឆ្នោតដើម្បីឱ្យគេអាចរាប់សន្លឹកឆ្នោតរបស់អ្នក ! រាល់ការរាប់សន្លឹកឆ្នោតគឺមានតម្លាភាព និងបើកទូលាយចំពោះការសង្កេតការជាសាធារណៈ ។

---

## ការបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់

**តើពេលណាទើបខ្ញុំអាចបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់បាន ?**

អ្នកអាចបោះឆ្នោតដោយបង្ហាញវត្តមានផ្ទាល់ក្នុងអំឡុងពេល បោះឆ្នោតមុនកាលកំណត់ ឬនៅថ្ងៃបោះឆ្នោត ។ រយៈពេលបោះឆ្នោតមុនកាលកំណត់នឹងចាប់ផ្តើមនៅថ្ងៃទី **17 ខែតុលា** និងបញ្ចប់នៅថ្ងៃទី **30 ខែតុលា** ។ អ្នកអាចពិនិត្យមើលកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង នៅលើគេហទំព័រ **www.MassEarlyVote.com** ។

នៅ **ថ្ងៃបោះឆ្នោត គឺថ្ងៃទី 3 ខែវិច្ឆិកា**ការិយាល័យបោះឆ្នោតនឹងបើកចាប់ពីម៉ោង 7 ព្រឹក ដល់ម៉ោង 8 យប់ ។ សូមចូលមើលគេហទំព័រ **www.WhereDoIVoteMA.com** ដើម្បីរកការិយាល័យបោះឆ្នោតរបស់អ្នក ។ អ្នកក៏អាចទូរស័ព្ទទៅនាយកដ្ឋានបោះឆ្នោតតាមលេខ 1-800-462- VOTE (8683) ដើម្បីសុំជំនួយក្នុងការរកការិយាល័យបោះឆ្នោតរបស់អ្នកផងដែរ ។

**តើខ្ញុំអាចរកឃើញការិយាល័យបោះឆ្នោត និងបេក្ខជនណាខ្លះ ដែលមាននៅលើសន្លឹកឆ្នោតរបស់ខ្ញុំដោយរបៀបណា ?**

សន្លឹកឆ្នោតគំរូ ក៏ដូចជាប័ណ្ណណែនាំ ត្រូវបានបិទប្រកាសនៅការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។ អ្នកក៏នឹងអាចមើលសន្លឹកឆ្នោតគំរូផងដែរនៅលើគេហទំព័រតាមអាសយដ្ឋាន **www.WhereDoIVoteMA.com** ។

**ខ្ញុំបានចុះឈ្មោះបោះឆ្នោត ប៉ុន្តែឈ្មោះរបស់ខ្ញុំមិនមាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោត—តើខ្ញុំត្រូវធ្វើដូចម្តេច ?**

បើសិនជាអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែមិនមានឈ្មោះរបស់អ្នកនៅក្នុងបញ្ជីបោះឆ្នោត សូមសួរមន្ត្រីរៀបចំការបោះឆ្នោតដែលទទួលបន្ទុកការិយាល័យបោះឆ្នោត ដើម្បីពិនិត្យមើលការចុះឈ្មោះរបស់អ្នកជាមួយស្មៀនក្រុង ដើម្បីមើលក្រែងលោអ្នកបានចុះឈ្មោះនៅមណ្ឌលផ្សេងនៅក្នុងទីក្រុងនោះ ។ បើសិនជាគេនៅតែមិនអាចរកឈ្មោះរបស់អ្នកឃើញទេ អ្នកអាចបោះសន្លឹកឆ្នោតបណ្តោះអាសន្ននៅការិយាល័យបោះឆ្នោតបាន ។ បន្ទាប់ពីការបោះឆ្នោតហើយ មន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋាននឹងស្វែងរកកំណត់ត្រានានា ដើម្បីបញ្ជាក់អំពីការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក ។ ប្រសិនបើលក្ខណៈសម្បត្តិរបស់អ្នកត្រូវបានបញ្ជាក់ សន្លឹកឆ្នោតរបស់អ្នកនឹងត្រូវបានរាប់ ។ ប្រសិនបើភាពមានសិទ្ធិបោះឆ្នោតរបស់អ្នក មិនអាចបញ្ជាក់បាននោះ សន្លឹកឆ្នោតរបស់អ្នកនឹងនៅតែបិទនៅក្នុងស្រោមសំបុត្រដដែល ។

**តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំគូសសន្លឹកឆ្នោតរបស់ខ្ញុំខុស ?**

ប្រសិនបើអ្នកគូសសន្លឹកឆ្នោតរបស់អ្នកខុស អ្នកអាចស្នើសុំសន្លឹកឆ្នោតថ្មីមួយទៀតបាន ។ លោកអ្នកអាចស្នើសុំសន្លឹកឆ្នោតថ្មីរហូតដល់ចំនួនពីរសន្លឹក ។

**តើខ្ញុំអាចនាំយកសម្ភារទៅក្នុងការិយាល័យបោះឆ្នោតបានឬទេ ?**

បាទ/ចាស៎ លោកអ្នកអាចនាំយកសម្ភារទៅក្នុងបន្ទប់បោះឆ្នោត ។ អ្នកអាចនាំយកខិត្តប័ណ្ណដែលបានបោះពុម្ពជាមុន ឬកូនសៀវភៅផ្សព្វផ្សាយ ឬកូនសៀវភៅកំណត់ត្រាផ្ទាល់ខ្លួនរបស់អ្នកមកបាន តែអ្នកមិនអាចបង្ហាញសម្ភារទាំងនោះបានទេ នៅខណៈពេលដែលអ្នកនៅក្នុងការិយាល័យបោះឆ្នោត ។ អ្នកត្រូវយកសម្ភារណាមួយទៅជាមួយអ្នក នៅពេលអ្នកចាកចេញពីតូបបោះឆ្នោត ។

# បញ្ឈប់ការរីករាលដាលនៃមេរោគ

## ជួយទប់ស្កាត់ការរីករាលដាលនៃជំងឺផ្លូវដង្ហើម ដូចជាជំងឺផ្តាសាយ និងជំងឺ COVID-19 ៖



ត្រូវលាងដៃរបស់អ្នកឱ្យបានញឹកញាប់ ជាមួយនឹងសាប៊ូ និងទឹកក្តៅឧណ្ហៗ ឬប្រើទឹកអាល់កុលលាងដៃ ។



ចៀសវាងការប៉ះ ភ្នែក ច្រមុះ និងមាត់របស់អ្នក ។



សម្អាតរបស់របរដែលឧស្សាហ៍ប៉ះ (ដូចជាដៃទ្វារ និងផ្ទៃតុ) ដោយក្រណាត់សើម ឬស្រ្តេយ៍បាញ់សម្អាតប្រើក្នុងគ្រួសារ ។



ត្រូវខ្ទប់មាត់ ពេលអ្នកក្អក ឬកណ្តាស់ ។ ប្រើក្រដាសជូតមាត់ ឬកែងដៃខាងក្នុងរបស់អ្នក មិនមែនប្រអប់ដៃរបស់អ្នកទេ ។



ចូរនៅផ្ទះ បើសិនជាអ្នកឈឺ និងចៀសវាងទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកដទៃ ។



ត្រូវគិតជាមុន អំពីរបៀបថែទាំខ្លួនរបស់អ្នក និងមនុស្សជាទីស្រឡាញ់របស់អ្នក ។
សូមចូលមើលគេហទំព័រ **mass.gov/KnowPlanPrepare** សម្រាប់គន្លឹះក្នុងការត្រៀមខ្លួន ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលគេហទំព័រ៖ **www.mass.gov/2019coronavirus**

Massachusetts Department of Public Health

3/9/2020

# ធ្វើជាមន្ត្រីរៀបចំការបោះឆ្នោត

វិធីមួយក្នុងចំណោមវិធីល្អបំផុតដែលអ្នកអាចជួយធ្វើឱ្យប្រាកដថារដ្ឋ Massachusetts ទទួលបានជោគជ័យក្នុងការបោះឆ្នោតនៅឆ្នាំនេះ គឺតាមរយៈការផ្តល់ពេលវេលារបស់អ្នកធ្វើជាមន្ត្រីរៀបចំការបោះឆ្នោត ។

គេត្រូវការមន្ត្រីរៀបចំការបោះឆ្នោតនៅទូទាំងរដ្ឋសហធន នៅថ្ងៃទី 3 ខែវិច្ឆិកា ហើយសហគមន៍ជាច្រើនក៏នឹងត្រូវការបុគ្គលិកដើម្បីជួយលើការបោះឆ្នោតមុនកាលកំណត់ផងដែរ ។

មន្ត្រីរៀបចំការបោះឆ្នោតត្រូវបានជួលដោយមន្ត្រីរៀបចំការបោះឆ្នោតឱ្យជួយចុះឈ្មោះអ្នកបោះឆ្នោត ចែកចាយសន្លឹកឆ្នោត រាប់សន្លឹកឆ្នោត និងជួយអ្នកបោះឆ្នោតនៅការិយាល័យបោះឆ្នោត ។ នៅឆ្នាំនេះ គេក៏ត្រូវការមន្ត្រីរៀបចំការបោះឆ្នោតដើម្បីជួយធ្វើអនាម័យតូប និងប៊ិច ណែនាំអ្នកបោះឆ្នោត និងត្រួតពិនិត្យគម្លាតសង្គមនៅការិយាល័យបោះឆ្នោតផងដែរ ។

ការមានមន្ត្រីរៀបចំការបោះឆ្នោតគ្រប់គ្រាន់សម្រាប់គ្រប់មណ្ឌល គឺជាវិធីល្អបំផុតដើម្បីធ្វើឱ្យអ្នកតម្រង់ជួរតិច និងកាត់បន្ថយការមានមនុស្សច្រើនកកកុញនៅការិយាល័យបោះឆ្នោត ។

ជាទូទៅ មន្ត្រីរៀបចំការបោះឆ្នោតត្រូវតែជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះហើយនៃរដ្ឋសហធន យ៉ាងណាក៏ដោយមានមន្ត្រីរៀបចំការបោះឆ្នោតរហូតដល់ 2 នាក់ក្នុងមួយមណ្ឌលដែលអាចមានអាយុ 16 ឬ 17 ឆ្នាំ ។ នៅឆ្នាំនេះ ប្រសិនបើសាលាក្រុងមិនអាចរកមន្ត្រីរៀបចំការបោះឆ្នោតបានគ្រប់គ្រាន់ទេ ពួកគេមានជម្រើសក្នុងការជួលបុគ្គលិកដោយមិនគិតពីស្ថានភាពនៃការចុះឈ្មោះ ឬសាខាគណបក្សនយោបាយឡើយ ។




បើសិនជាអ្នកអាចផ្តល់ពេលវេលាធ្វើជាមន្ត្រីរៀបចំការបោះឆ្នោតបាន សូមចូលមើលគេហទំព័ររបស់នាយកដ្ឋានបោះឆ្នោត **www.sec.state.ma.us/ele**ដែលនៅទីនោះអ្នកអាចរកឃើញបញ្ជីនៃក្រុងដែលត្រូវការមន្ត្រីរៀបចំការបោះឆ្នោត ។ ដើម្បីធ្វើជាមន្ត្រីរៀបចំការបោះឆ្នោតនៃក្រុងណាមួយ អ្នកមិនចាំបាច់ជាអ្នករស់នៅក្នុងក្រុងនោះទេ ។

## អ្នកបោះឆ្នោតជាយោធា និងនៅបរទេស

នៅរដ្ឋ Massachusetts សមាជិកដែលគ្រងឯកសណ្ឋានដែលកំពុង **បំពេញកាតព្វកិច្ចយោធា**ក្រុមគ្រួសាររបស់ពួកគេ និងពលរដ្ឋអាមេរិកដែលរស់នៅក្រៅប្រទេស មានសិទ្ធិបោះឆ្នោតនៅក្នុងការបោះឆ្នោតទាំងអស់ ។ អ្នកបោះឆ្នោតទាំងនេះ **មិនចាំបាច់ចុះឈ្មោះបោះឆ្នោត ដើម្បីស្នើសុំសន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមានទេ** ។ សន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមានអាចស្នើសុំដោយប្រើប្រាស់ទម្រង់ពាក្យសុំប័ណ្ណប្រៃសណីយ៍របស់សហព័ន្ធ ឬទម្រង់នៃការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរណាមួយ ឬ **សមាជិកក្រុមគ្រួសារអាចស្នើសុំ** ថាឲ្យគេផ្ញើសន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមានជូនអ្នកបោះឆ្នោតបាន ។

អ្នកបោះឆ្នោតទាំងនេះ អាចស្នើសុំថាសន្លឹកឆ្នោតបោះមុនដែលមិនអាចទៅស្ថានីយបោះឆ្នោតរបស់ពួកគេ ត្រូវផ្ញើទៅពួកគេតាមប៉ុស្តិ៍ប្រៃសណីយ៍ ទូរសា ឬតាមអ៊ីម៉ែល; សន្លឹកឆ្នោតក៏អាចត្រូវប្រគល់ជូនមន្ត្រីរៀបចំការបោះឆ្នោតនៅមូលដ្ឋានផងដែរ តាមវិធីសាស្ត្រទាំងនេះ ។

រដ្ឋ Massachusetts ក៏អនុញ្ញាតឱ្យអ្នកបោះឆ្នោតជាយោធា និងអ្នកបោះឆ្នោតនៅក្រៅប្រទេសបោះឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមាននៅក្នុងការបោះឆ្នោតទាំងអស់បាន ដោយប្រើសន្លឹកឆ្នោតបោះឆ្នោតអវត្តមានដោយសរសេរបញ្ចូលឈ្មោះបេក្ខជនដែលអត់មានឈ្មោះនៅលើសន្លឹកឆ្នោតរបស់សហព័ន្ធ (FWAB) បាន ។ FWAB អាចត្រូវប្រើប្រាស់ដើម្បីបោះឆ្នោតនៅពេលណាមួយមុនការបោះឆ្នោត ទោះបីជាអ្នកបោះឆ្នោតមិនបានដាក់ពាក្យសុំសន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមានក៏ដោយ ។ បន្ទាប់ពីការបោះឆ្នោតនៅលើ FWAB រួច អ្នកបោះឆ្នោតអាចផ្ញើវាតាមសំបុត្រ ឬតាមអេឡិចត្រូនិក ។ ទាំងពាក្យសុំប័ណ្ណជាមុនរបស់សហព័ន្ធ ទាំងសន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមានអាចរកបាននៅលើគេហទំព័ររបស់កម្មវិធីជំនួយបោះឆ្នោតសហព័ន្ធ **www.FVAP.gov** ។

# ប្រសិនបើអ្នកជាជនរងគ្រោះដោយសារការឆបោកខាងវិនិយោគ ការិយាល័យរដ្ឋលេខាធិការអាចជួយបាន !

ការិយាល័យលេខាធិការរបស់លោក Galvin ធ្វើនិយតកម្ម និងអនុវត្តច្បាប់នានាដែលទាក់ទងនឹងការវិនិយោគដែលមានហានិភ័យគ្រប់ប្រភេទ ដែលត្រូវបានផ្តល់ជូន ឬលក់នៅរដ្ឋ Massachusetts ។

ការិយាល័យលេខាធិការទទួលបានជោគជ័យក្នុងការប្រគល់ប្រាក់រាប់លានដុល្លារដោយផ្ទាល់ទៅកាន់វិនិយោគិនដែលត្រូវបានគេឆបោកវិញ ។

**សូមពិនិត្យមើលថាតើស្ថានភាពទាំងនេះដែលយើងខ្ញុំអាចជួយ គឺមានស្រដៀងគ្នានឹងអ្នកដែរឬទេ ៖**

ស្ត្រីមេម៉ាយវ័យចំណាស់ម្នាក់បានទៅសាខាធនាគារនៅមូលដ្ឋានរបស់គាត់ ដើម្បីដាក់ប្រាក់ក្នុងធនាគារដែលបានមកពីការលក់ទ្រព្យសម្បត្តិ ហើយអ្នកគួកជេរបានបញ្ចុះបញ្ចូលគាត់ឱ្យធ្វើវិនិយោគនៅក្នុងមូលនិធិផ្សារហ៊ុន និង CD ដែលទាក់ទងនឹងទីផ្សារ ។ អតិថិជនបានគេយល់ច្រឡំអំពីប្រភេទនៃការវិនិយោគ ពីព្រោះទ្រព្យសម្បត្តិបានលក់ឱ្យនាងនៅក្នុងសាខាធនាគារ ហើយឈ្មួញកណ្តាលបានជំទាស់នឹងបំណងប្រាថ្នាជាក់លាក់របស់នាង មិនមានការបង្ហាញទីផ្សារផ្សារហ៊ុនដោយដាក់នាងនៅក្នុងផលិតផលទាំងនោះ ។ អតិថិជនដែលបានទាក់ទងមកការិយាល័យលេខាធិការ និងអាចធ្វើប្រតិបត្តិការបញ្ច្រាសវិញ និងយកលុយទាំងអស់របស់គាត់បានមកវិញ ។

ឈ្មួញកណ្តាលទុច្ចរិតពីរនាក់ពីមេឈ្មួញកណ្តាលបានចូលរួមក្នុងការជួញដូរហួសប្រមាណនៅក្នុងគណនីមនុស្សចាស់ម្នាក់ ដើម្បីបង្កើតកម្រៃជើងសារខ្ពស់សម្រាប់ខ្លួនឯង ។ ភ្នាក់ងារទាំងនេះបានលាក់បាំងចំនួនទឹកប្រាក់ដែលបានគិតថ្លៃពីអតិថិជន ដូច្នេះគាត់មិនអាចរកឃើញថាទីភ្នាក់ងារទាំងនេះរកប្រាក់ទឹកតែពីគណនីរបស់គាត់ឡើយ ។ អតិថិជនដែលបានទាក់ទងការិយាល័យលេខាធិការ និងអាចទទួលបានមកវិញនូវកម្រៃមួយចំនួនដែលត្រូវបានគិតលើសលើគណនីរបស់គាត់ ហើយក្រុមហ៊ុនឈ្មួញកណ្តាលនោះត្រូវបានហាមឃាត់ជាអចិន្ត្រៃយ៍ពីការធ្វើជំនួញនៅរដ្ឋ Massachusetts ។

គូស្វាមីភរិយាវ័យចំណាស់ដែលបានទាក់ទងការិយាល័យលេខាធិការ ពីព្រោះប្រាក់ទាំងអស់របស់ពួកគាត់ត្រូវបានឈ្មួញកណ្តាលបញ្ចូលទៅក្នុងធនលាភប្រចាំឆ្នាំ ហើយបើមិនត្រូវបង់ថ្លៃយ៉ាងច្រើនទេ ពួកគាត់មិនអាចចូលយកប្រាក់របស់ពួកគេបានទេ ។ ការិយាល័យអាចជួយយកពួកគាត់ចេញពីធនលាភប្រចាំឆ្នាំដោយមិនចាំបាច់បង់ថ្លៃ ។

បុគ្គលម្នាក់បានបៀតបៀនលើសាច់ញាតិរបស់គាត់ ដើម្បីទទួលបានការគ្រប់គ្រងទាំងស្រុងលើគណនីឈ្មួញកណ្តាលរបស់ពួកគេ និងលួចលុយរបស់ពួកគេ ដើម្បីប្រើប្រាស់សម្រាប់ការចំណាយផ្ទាល់ខ្លួន ។ ពួកគាត់បានជូនដំណឹងដល់ការិយាល័យលេខាធិការនៅពេលដែលគាត់បានសារភាពនូវអ្វីដែលគាត់បានធ្វើ ហើយការិយាល័យបានធ្វើឱ្យក្រុមហ៊ុនឈ្មួញកណ្តាលសងប្រាក់ដែលបានលួច ។

គូស្វាមីភរិយាដែលចូលនិវត្តន៍ម្នាក់ បានជួលទីប្រឹក្សាវិនិយោគម្នាក់ ដើម្បីជួយពួកគេបញ្ហាហិរញ្ញវត្ថុរបស់ពួកគេ ។ គាត់បានដាក់វាចូលទៅក្នុងផលិតផលដែលគាត់បានរកកម្រៃជើងសារដ៏ច្រើន ប៉ុន្តែផលិតផលមិនសមស្របចំពោះតម្រូវការរបស់ពួកគេ ហើយគូស្វាមីភរិយានេះបានទទួលរងថ្លៃឈ្នួលយ៉ាងច្រើន ។ ការិយាល័យអាចជួយឱ្យពួកគេចេញពីផលិតផល និងធ្វើឱ្យពួកគេយកបានកម្រៃនោះមកវិញ ។

ឈ្មួញជើងសារធំៗបានខកខានផ្តល់ជូនការបង្ហាញព័ត៌មាន និងឯកសារគ្រប់គ្រាន់ដល់អតិថិជនចាស់ៗដែលទាក់ទងនឹងការគិតថ្លៃឈ្នួលពេលបោះបង់ការធានារ៉ាប់រង ដែលពួកគេបានទទួលរងនៅពេលអតិថិជននានាបានផ្លាស់ប្តូរប្រាក់ដែលត្រូវបង់ប្រចាំឆ្នាំដែលអាចប្រែប្រួល ។ ការិយាល័យលេខាធិការអាចធ្វើឲ្យឈ្មួញជើងសារសងថ្លៃបោះបង់ធានារ៉ាប់រងអាយុជីវិតដល់ពលរដ្ឋចាស់ជរានៃរដ្ឋ Massachusetts ។

ក្រុមហ៊ុនមួយបានបង់ប្រាក់ឲ្យបុគ្គលម្នាក់ធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម និងលក់ប័ណ្ណសន្យាសងប្រាក់ដែលមិនបានចុះបញ្ជីរបស់ខ្លួនដែលទាក់ទងនឹងអចលនទ្រព្យជូនដល់អ្នករស់នៅរដ្ឋ Massachusetts ។ ការិយាល័យលេខាធិការអាចឲ្យក្រុមហ៊ុនផ្តល់សំណងដល់វិនិយោគិនរដ្ឋ Massachusetts ទាំងអស់ និងបញ្ឈប់ការលក់ប័ណ្ណសន្យាសងប្រាក់នៅក្នុងរដ្ឋ Massachusetts ។ លើសពីនេះទៀតការិយាល័យរបស់គាត់បានរារាំងបុគ្គលនេះពីការចូលក្នុងវិស័យមូលបត្រនាពេលអនាគត ។

ប្រសិនបើអ្នកត្រូវការជំនួយ អ្នកអាចទាក់ទងការិយាល័យលេខាធិការដោយឥតគិតថ្លៃតាមរយៈលេខ 1-800-269-5428 ។

# សេវាកម្មនៃលេខាធិការសហគមន៍ឯករាជ្យនៃរដ្ឋម៉ាសាឈូសេត Massachusetts

**សេវាព័ត៌មានពលរដ្ឋ** មានមុខងារជាព័ត៌មានបឋម និងជាទីភ្នាក់ងារបញ្ជូនសម្រាប់រដ្ឋ ដែលផ្តល់ព័ត៌មានអំពីបណ្តាទីភ្នាក់ងារ និងកម្មវិធីរបស់រដ្ឋ ។ CIS ព្យាយាមឆ្លើយតបគ្រប់សំណើទាំងអស់ ដោយផ្តល់ជូនជំនួយផ្ទាល់ ឬអ្នកជំនាញត្រូវបញ្ជូនមកភ្លាមៗទៅកាន់ទីភ្នាក់ងារដែលសមស្រប ។ ជាផ្នែកមួយនៃគោលដៅរបស់ខ្លួន ដើម្បីធ្វើឱ្យរដ្ឋាភិបាលរដ្ឋអាចចូលដំណើរការបានចំពោះសាធារណជនកាន់តែច្រើនថែមទៀតនោះ CIS បានបង្កើតស៊េរីបោះពុម្ពផ្សាយប្រធានបទអំពីអត្ថប្រយោជន៍ជាក់លាក់ ដែលរួមមាន ៖

- មគ្គុទ្ទេសន៍របស់ពលរដ្ឋចំពោះសេវាកម្មរដ្ឋ ៖ បញ្ជីឈ្មោះដែលជ្រើសរើសសម្រាប់ទីភ្នាក់ងារ និងកម្មវិធីរបស់រដ្ឋាភិបាល ដោយមានអាសយដ្ឋាន លេខទូរស័ព្ទ និងការពណ៌នាអំពីទីភ្នាក់ងារ ។ តម្លៃ៖ $22.00 ($15 បូកថ្លៃឈ្នួលដឹកជញ្ជូន $7.00) ។ ចូលមើលតាមអ៊ិនធឺណិតឥតគិតថ្លៃលើ **www.sec.state.ma.us/cis/ciscig/guide.html** ។ អាចរកបានពីបណ្ណាគាររិមានរដ្ឋ ។
- រដ្ឋ Massachusetts សូមស្វាគមន៍ ៖ មគ្គុទ្ទេសន៍ជាក់ស្តែងក្នុងការរស់នៅក្នុងរដ្ឋ ដោយឥតគិតថ្លៃ ។
- អាការពិសេសលើរថយន្តឥតគិតថ្លៃ ។
- ការលើកលែងពន្ធលើអចលនទ្រព្យចំពោះមនុស្សចាស់ ប្តីឬប្រពន្ធដែលនៅរស់រានមានជីវិត និងអនីតិជនដោយឥតគិតថ្លៃ ។
- លំនៅដ្ឋានដែលមានអនាម័យ និងសុវត្ថិភាពសម្រាប់គេហជនរដ្ឋ Massachusetts - ឥតគិតថ្លៃ ។
- ច្បាប់ស្តីពីអតីតយុទ្ធជន និងការណែនាំអំពីអត្ថប្រយោជន៍ឥតគិតថ្លៃ ។
- ព័ត៌មានពិតអំពីរដ្ឋ Massachusetts ៖ ការពិនិត្យឡើងវិញនូវប្រវត្តិសាស្រ្ត រដ្ឋាភិបាល និងនិមិត្តសញ្ញារបស់រដ្ឋ សម្រាប់សិស្សដែលដល់អាយុចូលរៀនចាប់ពីមធ្យមសិក្សាបឋមភូមិរហូតដល់សាលាមធ្យមសិក្សាទុតិយភូមិវិទ្យាល័យដោយឥតគិតថ្លៃ ។

ទូរស័ព្ទ ៖ 617-727-7030 ឬ 1-800-392-6090 (លេខទូរស័ព្ទឥតគិតថ្លៃនៅក្នុង Massachusetts ប៉ុណ្ណោះ)
គេហទំព័រ៖ **www.sec.state.ma.us/cis**
អ៊ីមែល៖ cis@sec.state.ma.us

**នាយកដ្ឋានបោះឆ្នោត** គ្រប់គ្រងរាល់ការបោះឆ្នោតថ្នាក់រដ្ឋ ផ្តល់ព័ត៌មានអំពីការបោះឆ្នោត និងផ្គត់ផ្គង់សម្ភារបោះឆ្នោតដល់សាធារណជន បេក្ខជន និងមន្ត្រីរដ្ឋាភិបាល ។

ទូរស័ព្ទ៖ 617-727-2828 ឬ 1-800-462-VOTE (8683)
គេហទំព័រ៖ **www.sec.state.ma.us/ele**
អ៊ីមែល៖ elections@sec.state.ma.us

**នាយកដ្ឋានមូលប័ត្រ** ធ្វើការដើម្បីការពារវិនិយោគិនរដ្ឋ Massachusetts តាមរយៈការចុះឈ្មោះភ្នាក់ងារឈ្មួញជើងសារ និងអ្នកប្រឹក្សាខាងវិនិយោគ ដែលទាមទារឱ្យមានការចុះបញ្ជីមូលប័ត្រដែលមានហានិភ័យខ្ពស់ ការស៊ើបអង្កេតលើពាក្យបណ្តឹង និងចាត់វិធានការអនុវត្តច្បាប់ និងការដាក់វិន័យសមស្រប ។

ទូរស័ព្ទ ៖ 617-727-3548 ឬ 1-800-269-5428
គេហទំព័រ៖ **www.sec.state.ma.us/sct**
អ៊ីមែល៖ securities@sec.state.ma.us

**នាយកដ្ឋានកំណត់ត្រាសាធារណៈ** គ្រប់គ្រងច្បាប់ស្តីពីកំណត់ត្រាសាធារណៈ ជួយដល់បណ្តាទីភ្នាក់ងារ និងទីក្រុងដោយមានការគ្រប់គ្រងកំណត់ត្រា បញ្ជាក់ឯកសារសម្រាប់ប្រើប្រាស់នៅបរទេស អនុវត្តការស្បថចូលកាន់តំណែង និងរក្សាកំណត់ត្រានៃការណាត់ជួបគណៈកម្មការ និងអភិបាលរដ្ឋ ។

ទូរស័ព្ទ៖ 617-727-2832
គេហទំព័រ៖ **www.sec.state.ma.us/pre**
អ៊ីមែល៖ pre@sec.state.ma.us

**កំណត់ត្រាអចលនទ្រព្យ** ។ ព័ត៌មានអំពីការទាញយកសិទ្ធិជាម្ចាស់ និងផ្ទះកំណើត - រដ្ឋ Massachusetts ត្រូវបានបែងចែកជា 21 មណ្ឌលចុះបញ្ជីដោយមានការិយាល័យចុះបញ្ជីលិខិតផ្ទេរកម្មសិទ្ធិដែលបានជ្រើសរើស ដែលទទួលខុសត្រូវនៅតាមការិយាល័យនីមួយៗ ។ ឯកសារពាក់ព័ន្ធនឹងភាពជាម្ចាស់កម្មសិទ្ធិអចលនទ្រព្យនៅក្នុងមណ្ឌល ត្រូវបានកត់ត្រានៅការិយាល័យចុះបញ្ជីលិខិតផ្ទេរកម្មសិទ្ធិ ។

គេហទំព័រ ៖ **www.masslandrecords.com**

**ប័ណ្ណសាររដ្ឋ Massachusetts** ប្រមូល បែងចែកជាកាតាឡុក និងរក្សានូវកំណត់ត្រាដែលមានតម្លៃយូរអង្វែងតាំងពីជិត 400 ឆ្នាំរបស់រដ្ឋាភិបាលរដ្ឋ ។ កន្លែងទុកឯកសារបម្រើការជាធនធានដ៏សំខាន់ដល់សិស្ស អ្នកតំណពូជពង្ស និងនិស្សិត និងជាទីប្រឹក្សារបស់សហគមន៍កត់ត្រាប្រវត្តិសាស្រ្តនៅរដ្ឋម៉ាសាឈូសេត Massachusetts ។

ទូរស័ព្ទ៖ 617-727-2816
គេហទំព័រ៖ **www.sec.state.ma.us/arc**
អ៊ីមែល៖ archives@sec.state.ma.us

**សារមន្ទីរដ្ឋសហធន** ធ្វើឱ្យប្រវត្តិសាស្រ្តរដ្ឋ Massachusetts មានភាពរស់រវើកតាមរយៈការតាំងពិពណ៌ ការផ្សព្វផ្សាយ ព្រមទាំងកម្មវិធីនិស្សិត និងការបោះពុម្ពផ្សាយ ។

ទូរស័ព្ទ៖ 617-727-9268
គេហទំព័រ៖ **www.commonwealthmuseum.org**

**គណៈកម្មការប្រវត្តិសាស្ត្រនៃរដ្ឋ Massachusetts** គឺជាទីភ្នាក់ងាររបស់រដ្ឋដែលទទួលខុសត្រូវក្នុងការអភិរក្សប្រវត្តិសាស្ត្រនៅក្នុងរដ្ឋសហធន ។ គណៈកម្មការនេះផ្តល់ជំនួយដល់សហគមន៍នានាក្នុងការចុះបញ្ជីអចលនទ្រព្យជាមួយនឹងការិយាល័យចុះបញ្ជីទីកន្លែងប្រវត្តិសាស្ត្រថ្នាក់ជាតិ និងការបង្កើតមណ្ឌលប្រវត្តិសាស្ត្រនៅមូលដ្ឋាន ។

ទូរស័ព្ទ៖ 617-727-8470
គេហទំព័រ៖ **www.sec.state.ma.us/mhc**
អ៊ីមែល៖ mhc@sec.state.ma.us

**បណ្ណាគាររដ្ឋ** ផ្តល់ជូននូវសៀវភៅ និងខិតប័ណ្ណជាច្រើនដែលបោះពុម្ពផ្សាយដោយលេខាធិការនៃរដ្ឋសហធន និងទីភ្នាក់ងាររដ្ឋផ្សេងទៀត រួមទាំងក្រមបទបញ្ញានៃរដ្ឋ Massachusetts ។ កាតាឡុកបណ្ណាគារឥតគិតថ្លៃដែលអាចរកបាន ។

ទូរស័ព្ទ ៖ 617-727-2834
គេហទំព័រ៖ **www.sec.state.ma.us/spr**
អ៊ីមែល៖ bookstore@sec.state.ma.us

**ការិយាល័យតំបន់** នៅក្រុង Springfield និង Fall River ផ្តល់ជូននូវសេវាកម្មជាច្រើនដែលផ្តល់ដោយការិយាល័យទីក្រុង Boston និងនាំរដ្ឋាភិបាលរដ្ឋឱ្យខិតទៅជិតពលរដ្ឋនៃរដ្ឋ Massachusetts ។

Springfield៖ 413-784-1376
Fall River៖ 508-646-1374
គេហទំព័រ៖ **www.sec.state.ma.us/wso**

**នាយកដ្ឋានសាជីវកម្ម** ទទួលខុសត្រូវក្នុងការចុះបញ្ជីអង្គភាពអាជីវកម្មរកកម្រៃ និងមិនរកកម្រៃនៅរដ្ឋ Massachusetts និងផ្តល់ព័ត៌មានសង្ខេបភ្លាមៗអំពីអង្គភាពជិត 400,000 អង្គភាពដែលធ្វើអាជីវកម្មនៅក្នុងរដ្ឋនេះ ។

ទូរស័ព្ទ ៖ 617-727-2850 ឬ 617-727-9640
គេហទំព័រ ៖ **www.sec.state.ma.us/cor**
អ៊ីមែល៖ corpinfo@sec.state.ma.us

## នាយកដ្ឋានផ្សេងទៀតរួមមាន៖

**អ្នកបញ្ចុះបញ្ចូល៖**
ទូរស័ព្ទ៖ 617-727-9122
គេហទំព័រ៖ **www.sec.state.ma.us/lob**
អ៊ីមែល៖ lob@sec.state.ma.us

**ការបោះពុម្ពផ្សាយ និងបទបញ្ញារបស់រដ្ឋ**
ទូរស័ព្ទ ៖ 617-727-2831
គេហទំព័រ ៖ **www.sec.state.ma.us/spr**
អ៊ីមែល៖ regs@sec.state.ma.us

**ការដើរទស្សនកិច្ចតាម៉ោងរដ្ឋ ៖**
ទូរស័ព្ទ ៖ 617-727-3676
គេហទំព័រ ៖ **www.sec.state.ma.us/trs**
អ៊ីមែល៖ mastatehousetours@sec.state.ma.us

## ជំនួយសម្រាប់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ

រដ្ឋ Massachusetts ព្យាយាមការពារជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ ការរំលោភផ្លូវភេទ ការរំខានឬការបៀតបៀន ដោយជួយពួកគេរៀបចំអាសយដ្ឋានសម្ងាត់ថ្មី ដើម្បីការពារជនល្មើសនៃអំពើហិង្សាពីការស្វែងរកជនរងគ្រោះដែលបានផ្លាស់ប្តូរទីលំនៅ ។

កម្មវិធីនេះ ហៅថាកម្មវិធីភាពសម្ងាត់អាសយដ្ឋាន (ACP) ត្រូវបានគ្រប់គ្រងដោយលេខាធិការសហគមន៍ឯករាជ្យ ។

ដើម្បីបញ្ជាក់ថាជាអ្នកចូលរួមកម្មវិធីម្នាក់នោះ អ្នកដាក់ពាក្យសុំត្រូវបង្ហាញថា ការបង្ហាញព័ត៌មានអំពីអាសយដ្ឋានរបស់គាត់គំរាមកំហែងដល់សុវត្ថិភាពអ្នកដាក់ពាក្យសុំ ឬកូនៗរបស់អ្នកដាក់ពាក្យសុំ ។ ACP អនុញ្ញាតឱ្យអ្នកចូលរួមកម្មវិធីប្រើអាសយដ្ឋានផ្ញើសំបុត្រជំនួសវិញនៅពេលធ្វើការទាក់ទងជាមួយទីភ្នាក់ងាររដ្ឋាភិបាល ។ អាសយដ្ឋានជំនួសនេះ ត្រូវប្រើលំនៅដ្ឋានស្របច្បាប់របស់អ្នកចូលរួមកម្មវិធី ក៏ដូចជាអាសយដ្ឋានកន្លែងធ្វើការងារ និង/ឬសាលាផងដែរ ។ ហេតុនេះហើយកំណត់ត្រារបស់រដ្ឋាភិបាលអាចត្រូវផ្សព្វផ្សាយដល់សាធារណជនដោយមិនមានការកំណត់អត្តសញ្ញាណកន្លែងថ្មីរបស់ជនរងគ្រោះឡើយ ។

បណ្តាគ្រួសារមានប្រាក់ចំណូលទាបដែលត្រូវការជំនួយក្នុងការផ្លាស់ទីលំនៅ ដែលក្រៅពីនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ ACP អាចមានសិទ្ធិដាក់ពាក្យសុំជំនួយខាងលំនៅដ្ឋានដើម្បីបានមូលនិធិកម្មវិធីគ្រួសារដែលកំពុងស្ថិតនៅក្នុងអន្តរកាល (RAFT) ដែលជាកម្មវិធីគ្រប់គ្រងតាមរយៈក្រសួងលំនៅដ្ឋាន និងអភិវឌ្ឍន៍សហគមន៍ដែលអាចជួយបាននូវការចំណាយហិរញ្ញវត្ថុក្នុងរយៈពេលខ្លីលើការផ្លាស់ទីលំនៅ ដូចជាថ្លៃជួលខែដំបូង និងខែចុងក្រោយ និងប្រាក់កក់ដំបូងរហូតដល់ $4000 ។

**តើខ្ញុំអាចរកឃើញទីតាំងអ្នកជំនួយដាក់ពាក្យសុំ ដើម្បីចាប់ផ្តើមដំណើរការដាក់ពាក្យសុំដោយរបៀបណា ?**

អ្នកអាចហៅទូរស័ព្ទទៅ ACP តាមលេខ 1-866-SAFE-ADD ដើម្បីរកឃើញទីតាំងអ្នកជំនួយដាក់ពាក្យសុំ ។ លោកអ្នកក៏អាចទាក់ទងផងដែរទៅទីភ្នាក់ងារ ឬកម្មវិធីមិនរកប្រាក់ចំណេញដែលផ្តល់ជូនការប្រឹក្សាយោបល់ អ្នកជំនាញត្រូវបញ្ជូនមក ទីជម្រក ឬសេវាកម្មពិសេសផ្សេងទៀតដល់ជនរងគ្រោះពីការរំលោភបំពានក្នុងគ្រួសារ ការរំលោភបំពានផ្លូវភេទ ឬការរំខានឬការបៀតបៀនដែលមិនចង់បាន ។ ការអនុវត្តគម្លាតសង្គមសមស្របត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការដាក់ពាក្យសុំ ACP សម្រាប់អ្នកគាំពារខាងអំពើហិង្សាក្នុងគ្រួសារដែលទទួលពាក្យសុំ ក៏ដូចជាជនរងគ្រោះដែលពួកគេជួយនៅក្នុងរយៈពេលជំងឺរាតត្បាត COVID19 នេះផងដែរ ។

# សេចក្តីប្រកាសសិទ្ធិឯកជនរបស់អ្នកបោះឆ្នោតនៅរដ្ឋ Massachusetts

**សិទ្ធិបោះឆ្នោតរបស់អ្នកត្រូវបានការពារ ។ សិទ្ធិទាំងនេះត្រូវបានធានាដល់អ្នកបោះឆ្នោតដែលចុះឈ្មោះដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។**

1. អ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើអ្នកជាអ្នកបោះឆ្នោតដែលចុះឈ្មោះដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

2. អ្នកមានសិទ្ធិបោះឆ្នោតរបស់អ្នកក្នុងលក្ខណៈដែលធានាសិទ្ធិឯកជនភាព ។ លោកអ្នកមានសិទ្ធិបោះឆ្នោតដោយគ្មានបុគ្គលណាម្នាក់ព្យាយាមមានឥទ្ធិពលលើការបោះឆ្នោតរបស់អ្នកនិងដើម្បីបោះឆ្នោតនៅក្នុងបន្ទប់បោះឆ្នោតដែលរាំងអ្នកដទៃពីការមើលឃើញលោកអ្នកគូសសន្លឹកឆ្នោតរបស់អ្នក ។

3. លោកអ្នកមានសិទ្ធិស្ថិតនៅក្នុងបន្ទប់បោះឆ្នោតក្នុងរយៈពេលប្រាំ(5) នាទី បើមានអ្នកបោះឆ្នោតផ្សេងទៀតកំពុងរង់ចាំ និងរយៈពេលដប់ (10) នាទី បើគ្មានអ្នកបោះឆ្នោតផ្សេងទៀតរង់ចាំ ។

4. អ្នកមានសិទ្ធិទទួលបានសន្លឹកឆ្នោតថ្មីរហូតដល់ពីរ (2)សន្លឹក ប្រសិនបើអ្នកគូសខុស ហើយធ្វើឲ្យខូចសន្លឹកឆ្នោតរបស់អ្នក ។

5. អ្នកមានសិទ្ធិស្នើសុំជំនួយនៅពេលបោះឆ្នោតពីអ្នកណាម្នាក់តាមការជ្រើសរើសរបស់អ្នក ។ ប្រសិនបើអ្នកមិននាំអ្នកណាម្នាក់មកជាមួយអ្នកទេ អ្នកមានសិទ្ធិទទួលជំនួយពីមន្ត្រីរៀបចំការបោះឆ្នោតចំនួនពីរ (2) នាក់ ។

6. អ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើអ្នកជាជនពិការ ។ កន្លែងបោះឆ្នោតត្រូវតែអាចចូលបាន ហើយត្រូវមានបន្ទប់បោះឆ្នោតដែលអាចប្រើប្រាស់បាន ។

7. អ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើអ្នកមិនអាចអាន ឬសរសេរ ឬមិនអាចអាន ឬសរសេរភាសាអង់គ្លេសបាន ។

8. អ្នកមានសិទ្ធិបោះឆ្នោត ប៉ុន្តែត្រូវបង្ហាញអត្តសញ្ញាណប័ណ្ណ ប្រសិនបើ៖អ្នកជាអ្នកបោះឆ្នោតលើកដំបូងដែលបានចុះឈ្មោះបោះឆ្នោតតាមសំបុត្រ និងមិនបានដាក់ជូនអត្តសញ្ញាណប័ណ្ណជាមួយទម្រង់ចុះឈ្មោះបោះឆ្នោត ឬឈ្មោះរបស់អ្នកនៅក្នុងបញ្ជីបោះឆ្នោតអសកម្ម ឬការបោះឆ្នោតរបស់អ្នកកំពុងមានបញ្ហាប្រឈម ឬប្រសិនបើបានស្នើសុំដោយមន្ត្រីរៀបចំការបោះឆ្នោត ។ ទម្រង់អត្តសញ្ញាណប័ណ្ណដែលអាចទទួលយកបាន ៖ ប័ណ្ណបើកបរនៅរដ្ឋ Massachusetts ឯកសារដែលបោះពុម្ពផ្សេងទៀត ដែលមានឈ្មោះ និងអាសយដ្ឋានរបស់អ្នក ដូចជាសំបុត្រទារថ្លៃយូធីលីធីថ្មី បង្កាន់ដៃបង់ប្រាក់ជួលដែលមានលើក្បាលលិខិតរបស់ម្ចាស់ផ្ទះជួល កិច្ចសន្យាជួល ឬឯកសារថតចម្លងមួយច្បាប់ពីការទទួលស្គាល់ ឬបង្កាន់ដៃចុះឈ្មោះអ្នកបោះឆ្នោត ។

9. អ្នកមានសិទ្ធិបោះឆ្នោតតាមសន្លឹកឆ្នោតសម្រាប់អ្នកបោះឆ្នោតអវត្តមាន ប្រសិនបើ ៖ អ្នកនឹងអវត្តមានពីទីក្រុង ឬក្រុងរបស់អ្នកនៅថ្ងៃបោះឆ្នោតឬប្រសិនបើអ្នកមានពិការភាពផ្នែករាងកាយដែលរារាំងការបោះឆ្នោតរបស់អ្នកនៅការិយាល័យបោះឆ្នោត ឬប្រសិនបើអ្នកមិនអាចបោះឆ្នោតនៅការិយាល័យបោះឆ្នោតដោយសារតែជំនឿសាសនា ។

10. លោកអ្នកមានសិទ្ធិឆ្នោតតាមសន្លឹកបណ្តោះអាសន្នមួយ ប្រសិនបើលោកអ្នកជឿជាក់ថា លោកអ្នកជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ប៉ុន្តែបុគ្គលិករៀបចំការបោះឆ្នោតប្រាប់លោកអ្នកថា លោកអ្នកមិនមានសិទ្ធិបោះឆ្នោត ។

11. លោកអ្នកមានសិទ្ធិតាមដានបញ្ហាប្រឈមណាមួយចំពោះសិទ្ធិបោះឆ្នោតរបស់អ្នកតាមរយៈដំណើរការបណ្តឹងតវ៉ា ។

12. អ្នកមានសិទ្ធិបោះឆ្នោត ប្រសិនបើបច្ចុប្បន្នអ្នកមិនជាប់ឃុំឃាំងចំពោះការផ្តន្ទាទោសបទឧក្រិដ្ឋ ហើយបានចុះឈ្មោះជាអ្នកបោះឆ្នោតម្នាក់បន្ទាប់ពីការដោះលែងអ្នក ។

13. លោកអ្នកមានសិទ្ធទទួលយកសេចក្តីប្រកាសសិទ្ធិឯកជនរបស់អ្នកបោះឆ្នោត ឬឯកសារផ្សេងទៀត ដែលរួមមានសន្លឹកឆ្នោតគំរូមគ្គុទ្ទេសក៍អ្នកបោះឆ្នោត ឬសម្ភារយុទ្ធនាការឃោសនាបោះឆ្នោតចូលទៅក្នុងបន្ទប់បោះឆ្នោតជាមួយលោកអ្នក ។ សូមចងចាំថា ត្រូវយកក្រដាសស្នាមទាំងអស់ចេញនៅពេលអ្នកចាកចេញពីតូបបោះឆ្នោត ។

14. អ្នកមានសិទ្ធិបោះឆ្នោតនៅការិយាល័យបោះឆ្នោតរបស់អ្នកគ្រប់ពេលវេលានៅចន្លោះម៉ោង 7 ព្រឹក និង 8 យប់ សម្រាប់ការបោះឆ្នោតរដ្ឋ និងសហព័ន្ធ—ម៉ោងអាចប្រែប្រួលសម្រាប់ការបោះឆ្នោតនៅមូលដ្ឋាន ។ ប្រសិនបើអ្នកឈរតម្រង់ជួរនៅការិយាល័យបោះឆ្នោតរបស់អ្នកនៅពេលការិយាល័យបោះឆ្នោតបិទនៅម៉ោង 8 យប់ អ្នកមានសិទ្ធិបោះឆ្នោត ។

15. អ្នកមានសិទ្ធិនាំកូនៗរបស់អ្នកចូលក្នុងតូបបោះឆ្នោតជាមួយអ្នកបាន ។

ប្រសិនបើលោកអ្នកមានអារម្មណ៍ថាសិទ្ធិបោះឆ្នោតរបស់អ្នកត្រូវបានគេរំលោភបំពានតាមរបៀបណាមួយនោះ សូមហៅទូរស័ព្ទទៅផ្នែកការបោះឆ្នោតនៃលេខាធិការសហគមន៍ឯករាជ្យ តាមទូរស័ព្ទលេខ 1-800-462-VOTE (8683) ។ ការហៅទូរស័ព្ទនេះគឺឥតគិតថ្លៃនៅក្នុងរដ្ឋ Massachusetts ។

# ✘ បញ្ជីពិនិត្យឈ្មោះអ្នកបោះឆ្នោត

*សូមហែកសន្លឹកឆ្នោត ហើយយកទៅកាន់ការិយាល័យបោះឆ្នោត ។*

**សន្លឹកឆ្នោត ▶ សំណួរ** សំណួរទី 1 ☐ បាទ/ចាស ☐ ទេ

សំណួរទី 2 ☐ បាទ/ចាស ☐ ទេ

**សន្លឹកឆ្នោត ▶ មុខតំណែង** **មុខតំណែងនៅលើសន្លឹកឆ្នោតនៅឆ្នាំ 2020 មានដូចខាងក្រោម ៖**

**ប្រធាន/អនុប្រធាន** ______________________________

**សមាជិកព្រឹទ្ធសភានៅក្នុងសភា** ______________________________

**អ្នកតំណាងនៅក្នុងសភា** ______________________________

**ក្រុមប្រឹក្សា** ______________________________

**សមាជិកព្រឹទ្ធសភានៅតុលាការធម្មតា** ______________________________

**អ្នកតំណាងនៅតុលាការធម្មតា** ______________________________

**ការចុះបញ្ជីលិខិតមរតក** ______________________________

**ស្នងការខោនធី** (សូមជ្រើសរើសខោនធី) ______________________________

**ហិរញ្ញិកខោនធី** (សូមជ្រើសរើសខោនធី) ______________________________

**នគរបាល** (តែខោនធី Norfolk ប៉ុណ្ណោះ – ដើម្បីបំពេញកន្លែងនៅទំនេរ) ______________________________

**William Francis Galvin**
Secretary of the Commonwealth
One Ashburton Place, Room 1705
Boston, MA 02108

Non-Profit Org.
ECRWSS
U.S. Postage
**PAID**
Massachusetts
Secretary of the
Commonwealth

OFFICIAL ELECTION MAIL
Authorized by the U.S. Postal Service ®

ឯកសារផ្លូវការ

# *ការបោះឆ្នោតសម្រាប់អតិថិជនតាមលំនៅដ្ឋាន*

**ព័ត៌មានសម្រាប់អ្នកបោះឆ្នោត** ត្រូវបានផ្ញើទៅអ្នកបោះឆ្នោតនានាតាមសំបុត្រទៅអាសយដ្ឋានលំនៅដ្ឋាន ទៅអ្នកបោះឆ្នោតនានាដែលរស់នៅក្នុងសង្កាត់រស់នៅជាក្រុម និងទីកន្លែងសាធារណៈដែលងាយស្រួលនៅទូទាំងរដ្ឋសហធន ។ ច្បាប់ចម្លងដែលមានកំណត់បន្ថែមអាចទទួលបាននៅតាមសាលាក្រុងមូលដ្ឋាន និងបណ្ណាបណ្ណាល័យមួយចំនួន ឬតាមរយៈការហៅទូរស័ព្ទទៅនាយកដ្ឋានបោះឆ្នោតនៃលេខាធិការ Galvin តាមរយៈលេខ 617-727-2828 ឬ 1-800-462-VOTE (8683) ឬសេវាកម្មព័ត៌មានពលរដ្ឋតាមរយៈ 617-727-7030 ឬ 1-800-392-6090 ។ អ្នកប្រើប្រាស់ TTY អាចទូរស័ព្ទទៅកាន់ MassRelay តាមលេខ 800-720-3480 ។ ត្រូវប្រាកដថា ចូលមើលគេហទំព័ររបស់យើងតាមអាសយដ្ឋាន **www.sec.state.ma.us** ។ ការបោះពុម្ពផ្សាយព័ត៌មានជាភាសាអេស្ប៉ាញ ចិន និងខ្មែរសម្រាប់អ្នកបោះឆ្នោត និងការបោះពុម្ពធំសម្រាប់អ្នកដែលមានបញ្ហាភ្នែកក៏អាចរកបានផងដែរតាមលេខទូរស័ព្ទដូចគ្នានេះ ។ កំណែជាសំឡេងក៏អាចរកបានពីបណ្ណាល័យ Braille and Talking Book Library នៅ Watertown ផងដែរ តាមទូរស័ព្ទលេខ 1-800-852-3133 ។

♻ បោះពុម្ពលើក្រដាសកែច្នៃឡើងវិញ